

ASIA LOW CARBON BUILDINGS TRANSITION PROJECT

*Life Cycle Assessment for Transitioning to a Low-Carbon Economy*

# ១.១

# សេណារីយ៉ូថាមពល និង កម្មវិធីប្រសិទ្ធភាពថាមពលសម្រាប់អគារ

- ទិដ្ឋភាពទូទៅអំពីប្រសិទ្ធិភាពថាមពលនៅអាស៊ាន និងឥណ្ឌា
- កម្ពុជា៖ ផែនការជាតិរួមចំណែកឆ្លើយតបការប្រែប្រួលអាកាសធាតុ **(NDCs)** និងគម្រោងប្រសិទ្ធភាពថាមពលសម្រាប់អគារ **(BEEP)**

ខែកុម្ភៈ ឆ្នាំ២០២៦

Supported by:

Federal Ministry for the Environment, Climate Action, Nature Conservation and Nuclear Safety

INTERNATIONAL CLIMATE INITIATIVE

based on a decision of the German Bundestag

# អក្សរកាត់

| អក្សរកាត់ | ទម្រង់ពេញ |
|---|---|
| ALCBT | គម្រោងជំរុញអន្តរកាលអគារកាបូនទាបក្នុងតំបន់អាស៊ី (Asia Low Carbon Buildings Transition) |
| ASEAN | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (Association of Southeast Asian Nations) |
| BAU | ការព្យាករតាមទម្លាប់ធម្មតា (Business as usual) |
| BEC | ក្រមថាមពលអគារ (Building Energy Code) |
| BEEP | គម្រោងប្រសិទ្ធិភាពថាមពលសម្រាប់អគារ (Building Energy Efficiency Project) |
| CCMB | អាកាសធាតុ ឆ្នេរសមុទ្រ និងជីវចម្រុះសមុទ្រ (Climate, Coastal and Marine Biodiversity) |
| CCUS | ការចាប់យក ការប្រើប្រាស់ និងការផ្ទុកកាបូន (Carbon Capture, Utilization, and Storage) |
| COP | សន្និសីទនៃភាគី (Conference of Parties) |
| CTCN | មជ្ឈមណ្ឌលបច្ចេកវិទ្យាអាកាសធាតុ និងបណ្តាញទំនាក់ទំនង (Climate Technology Center and Network) |
| DCCE | នាយកដ្ឋានការប្រែប្រួលអាកាសធាតុ និងបរិស្ថាន (Department of Climate Change and Environment) |
| DEDE | នាយកដ្ឋានអភិវឌ្ឍន៍ថាមពលជំនួស និងប្រសិទ្ធភាព (Department of Alternative Energy Development and Efficiency) |
| DR | ការឆ្លើយតបតាមតម្រូវការ (Demand Response) |
| DSM | ការគ្រប់គ្រងផ្នែកតម្រូវការថាមពល (Demand Side Management) |
| EE | ប្រសិទ្ធភាពថាមពល (Energy Efficiency) |
| ECBC | ច្បាប់សន្សំសំចៃថាមពលសម្រាប់អគារ (Energy Conservation Building Code) |
| EEC | ច្រករបៀងសេដ្ឋកិច្ចបូព៌ា (ប្រទេសថៃ) Eastern Economic Corridor (Thailand) |
| EERS | ស្តង់ដារប្រភពប្រសិទ្ធិភាពថាមពល (Energy Efficiency Resource Standards) |
| EESL | សេវាប្រសិទ្ធភាពថាមពល (Energy Efficiency Services Ltd.) |

# អក្សរកាត់

| អក្សរកាត់ | ទម្រង់ពេញ |
|---|---|
| EGAT | អាជ្ញាធរផលិតកម្មអគ្គិសនីថៃ (Electricity Generating Authority of Thailand) |
| ESCO | ក្រុមហ៊ុនផ្តល់សេវាថាមពល (Energy Service Company) |
| ETS | ប្រព័ន្ធពាណិជ្ជកម្មលើការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ (Emission Trading System) |
| EV | រថយន្តអគ្គិសនី (Electric Vehicle) |
| EUR | អឺរ៉ូ (Euro) |
| GDP | ផលិតផលក្នុងស្រុកសរុប (Gross Domestic Product) |
| GEF | បរិក្ខារ បរិស្ថានសកល (Global Environment Facility) |
| GEM | ចលនាបៃតង និងបរិស្ថានមេត្រី (Green and Eco-friendly Movement) |
| GGGI | វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល (Global Green Growth Institute) |
| GHG | ឧស្ម័នផ្ទះកញ្ចក់ (Greenhouse Gas) |
| GIZ | ទីភ្នាក់ងារកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ (The Deutsche Gesellschaft für Internationale Zusammenarbeit) |
| GRIHA | ចំណាត់ថ្នាក់បៃតងសម្រាប់ការវាយតម្លៃលំនៅដ្ឋានរួមបញ្ចូលគ្នា (Green Rating for Integrated Habitat Assessment) |
| GW | ហ្គីហ្គាវ៉ាត់( Giga Watt) |
| IEA | ទីភ្នាក់ងារថាមពលអន្តរជាតិ (International Energy Agency) |
| IGBC | ក្រុមប្រឹក្សាអគារបៃតងឥណ្ឌា (Indian Green Building Council) |
| IIEC | វិទ្យាស្ថានអន្តរជាតិដើម្បីការអភិរក្សថាមពល (International Institute for Energy Conservation) |
| IEAT | អាជ្ញាធរអចលនទ្រព្យឧស្សាហកម្មថៃ (Industrial Estate Authority of Thailand) |
| IPCC | ក្រុមប្រឹក្សាអន្តររដ្ឋាភិបាលស្តីពីបំរែបំរួល អាកាសធាតុ (Intergovernmental Panel on Climate Change) |

# អក្សរកាត់

| អក្សរកាត់ | ទម្រង់ពេញ |
|---|---|
| IRENA | ទីភ្នាក់ងារថាមពលកកើតឡើងវិញអន្តរជាតិ (International Renewable Energy Agency) |
| LEED | ភាពជាអ្នកដឹកនាំក្នុងការរចនាថាមពល និងបរិស្ថាន (Leadership in Energy and Environmental Design) |
| LT-LEDS | យុទ្ធសាស្ត្រអភិវឌ្ឍន៍ការបញ្ចេញឧស្ម័នទាបរយៈពេលវែង (Long Term Low Emissions Development Strategy) |
| LULUCF | ការប្រើប្រាស់ដី ការផ្លាស់ប្តូរការប្រើប្រាស់ដី និងព្រៃឈើ (Land Use, Land Use Change, and Forestry) |
| MEPS | បទដ្ឋានគុណផលថាមពលអប្បបរមា(Minimum Energy Performance Standard) |
| MONRE | ក្រសួងធនធានធម្មជាតិ និងបរិស្ថាន (Ministry of Natural Resources and Environment) |
| Mtoe | លានតោននៃសមមូលប្រេង (Million tons of oil equivalent) |
| NCAP | ផែនការសកម្មភាពសីតកម្មជាតិ(National Cooling Action Plan) |
| NDC | ផែនការជាតិរួមចំណែកឆ្លើយតបការប្រែប្រួលអាកាសធាតុ (Nationally Determined Contributions) |
| OEC | ការិយាល័យគណៈកម្មាធិការបទប្បញ្ញត្តិថាមពល (Office of Energy Regulatory Commission) |
| ONEP | ការិយាល័យគោលនយោបាយ និងផែនការធនធានធម្មជាតិ និងបរិស្ថាន (Office of Natural Resources and Environmental Policy and Planning) |
| OTP | ការិយាល័យគោលនយោបាយ និងផែនការដឹកជញ្ជូន និងចរាចរណ៍ (Office of Transport Policy and Planning and Traffic) |
| PES | សេណារីយ៉ូថាមពលដែលបានគ្រោងទុក (Planned Energy Scenario) |
| PPAC | ផ្នែកផែនការនិងវិភាគប្រេងកាត (Petroleum Planning & Analysis Cell) |
| PPP | ភាពស្មើគ្នានៃអំណាចទិញ (Purchasing Power Parity) |
| RE | ថាមពលកកើតឡើងវិញ (Renewable Energy) |
| RECs | វិញ្ញាបនបត្រថាមពលកកើតឡើងវិញ (Renewable Energy Certificates) |

# អក្សរកាត់

| អក្សរកាត់ | ទម្រង់ពេញ |
|---|---|
| tCO2e | តោននៃសមមូលឧស្ម័នកាបូនិច (Tons of Carbon dioxide equivalent) |
| TREES | ការផ្តល់ចំណាត់ថ្នាក់របស់ថៃលើនិរន្តរភាពថាមពល និងបរិស្ថាន (Thai Rating on Energy and Environment Sustainability) |
| TWh | តេរ៉ាវ៉ាត់ម៉ោង (Terra Watt hours) |
| UK | ចក្រភពអង់គ្លេស (United Kingdom) |
| UNDP | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (United Nations Development Program) |
| UNEP | កម្មវិធីបរិស្ថានសហប្រជាជាតិ(United Nations Environment Program) |
| UNIDO | អង្គការអភិវឌ្ឍន៍ឧស្សាហកម្មសហប្រជាជាតិ (United Nations Industrial Development Organization) |
| UN ESCAP | គណៈកម្មការសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិសម្រាប់តំបន់អាស៊ី និងប៉ាស៊ីហ្វិក (United Nations Economic and Social Commission for Asia and the Pacific) |
| UNFCCC | អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីបំរែបំរួល អាកាសធាតុ (United Nations Framework Convention on Climate Change) |
| USD | ដុល្លារអាមេរិក (United States Dollar) |
| REDD | កាត់បន្ថយការបំភាយឧស្ម័នពីការកាប់បំផ្លាញព្រៃឈើ និងការរិចរិលព្រៃឈើ (Reducing Emissions from Deforestation and Forestation Degradation) |

# តើអ្នកនឹងសិក្សាអ្វីខ្លះ?

១ អំពីគម្រោង ALCBT

២ បំរែបំរួលអាកាសធាតុ និងផលប៉ះពាល់

៣ សេណារីយ៉ូ ថាមពល

៤ NDCs របស់អាស៊ី ខាងត្បូង

៥ NDCs និង គំនិតផ្តួចផ្តើម របស់កម្ពុជា

៦ បញ្ហាប្រឈម និងឱកាស នៅកម្ពុជា



# គម្រោង ALCBT

## កម្ពុជា ឥណ្ឌា ឥណ្ឌូណេស៊ី ថៃ និងវៀតណាម



ប្រភពរូបភាព៖ https://eacnews.asia/home/details/30108

# គម្រោង ALCBT

## សាវតាគម្រោងជំរុញអន្តរកាលអគារកាបូនទាបក្នុងតំបន់អាស៊ី

**គោលបំណង:**
ដើម្បីបង្ហាញយុទ្ធសាស្ត្រដែលបានបង្កើតឡើងដើម្បីផ្លាស់ប្តូរអគារដែលមានស្រាប់ និងអគារថ្មីឆ្ពោះទៅរកអព្យាក្រឹតភាពកាបូននៅមុន ឬត្រឹមឆ្នាំ 2050 ។ ការយល់ដឹងអំពីការអនុវត្តការសាងសង់ប្រកបដោយនិរន្តរភាព នឹងធ្វើអោយប្រសើរឡើងនូវលក្ខខណ្ឌរស់នៅ និងកាត់បន្ថយដានកាបូនពីវិស័យអគារ។

**សាវតា៖**
វិស័យអគារ និងសំណង់រួមចំណែកយ៉ាងសំខាន់ចំពោះការប្រែប្រួលអាកាសធាតុសកល ដែលស្មើនឹងប្រហែល 21% នៃការបំភាយឧស្ម័នផ្ទះកញ្ចក់សរុប។

- កាបូនបង្កប់មានចំនួនប្រហែល 10% នៃថាមពលសកលដែលទាក់ទងនឹងការបំភាយ GHG។ ផ្ទៃអាគារសកលសរុបនឹងកើនឡើងទ្វេដងនៅឆ្នាំ 2060 ដែលភាគច្រើនស្ថិតនៅតំបន់អាស៊ី និងអាហ្វ្រិក។
- ការប្រតិបត្តិការអគារតំណាងឱ្យប្រហែល 30% នៃតម្រូវការថាមពលចុងក្រោយ ក្នុងនោះច្រើនជាង 20% ស្ថិតនៅតំបន់អាស៊ីដែលមានកំណើនការប្រើប្រាស់ថាមពលចុងក្រោយខ្ពស់បំផុត ដើម្បីផ្តល់ភាពត្រជាក់សម្រាប់អគារ។

*Sources: IEA, UNEP, GlobalABC Global Status Report*

# គម្រោង ALCBT

## សាវតាគម្រោងជំរុញអន្តរកាលអគារកាបូនទាបក្នុងតំបន់អាស៊ី

**អត្ថប្រយោជន៍:** ការផ្លាស់ប្តូរទូទាំងប្រទេសឆ្ពោះទៅរកអគារកាបូនទាបក្នុងបណ្តាប្រទេសក្នុងតំបន់អាស៊ី និងកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់យ៉ាងច្រើនពីវិស័យនេះ។

**លទ្ធផលដែលបានកំណត់:** ឧបករណ៍បច្ចេកទេស ផែនការ និងយន្តការសម្រាប់អគារកាបូនទាប ត្រូវបានអនុវត្តដោយជោគជ័យដោយភាគីពាក់ព័ន្ធក្នុងវិស័យសាធារណៈ និងឯកជនសំខាន់ៗនៅក្នុងប្រទេសកម្ពុជា ឥណ្ឌា ឥណ្ឌូនេស៊ី ថៃ និងវៀតណាម។



**រយៈពេលអនុវត្តគម្រោង:**
សីហា ឆ្នាំ២០២៣ ដល់ខែសីហា ឆ្នាំ២០២៨

### គោលដៅអ្នកទទួលផលពីគម្រោង

- មន្ត្រីរាជរដ្ឋាភិបាល
- វិស័យអគារ និងសំណង់
- វិស័យហិរញ្ញវត្ថុ
- សិក្សាធិការ

**មូលនិធិគម្រោង៖ 19.3 លានអឺរ៉ូ**

### លទ្ធផលចម្បងរបស់គម្រោង

- ការបង្កើត ឧបករណ៍និងយន្តការ ផ្លាស់ប្តូរទៅរកអគារកាបូនទាប
- ការកសាងសមត្ថភាព ដល់ភាគីពាក់ព័ន្ធសំខាន់ៗ
- យន្តការហិរញ្ញវត្ថុ សម្រាប់ការផ្លាស់ប្តូរទៅរកអគារកាបូនទាប
- ការចែករំលែក ចំណេះដឹង និងសមិទ្ធផលគម្រោង

| | | |
|---|---|---|
| កាត់បន្ថយសរុប 1.68 លាន $tCO_2e$ នៃការការបំភាយដោយផ្ទាល់ និងប្រយោល | សរុប 19,000+ នាក់ ដែលបានបង្កើនជំនាញ | 140 លានអឺរ៉ូ កៀរគរប្រាក់វិនិយោគសរុប |

# ALCBT PROJECT

## Overall project structure

| | | | | |
|---|---|---|---|---|
| Project Steering Committee | Government Representatives + Industry Representatives:<br>**Cambodia, India, Indonesia, Thailand, Vietnam**<br>Consortium Representatives + ZUG<br>Meets virtually annually, in line with annual donor reports. | | | |
| Consortium partners | Global Green Growth Institute (GGGI) | HEAT International (HEAT) | ASEAN Centre for Energy (ACE) | Energy Efficiency Services Limited (EESL) |
| | Meets virtually monthly, to share project updates. | | | |
| **Technical Advisory Committee** | | | | |

# គម្រោង ALCBT
## រចនាសម្ព័ន្ធអភិបាលកិច្ច

**គណៈកម្មាធិការដឹកនាំគម្រោង**

តំណាងរដ្ឋាភិបាល + តំណាងវិស័យ៖
កម្ពុជា ឥណ្ឌា ឥណ្ឌូនេស៊ី ថៃ វៀតណាម
តំណាងសម្ព័ន្ធ + ZUG

កិច្ចប្រជុំរៀងរាល់ឆ្នាំ ស្របតាមរបាយការណ៍ម្ចាស់ជំនួយប្រចាំឆ្នាំ។

**សម្ព័ន្ធដៃគូ**

| | | | |
|---|---|---|---|
| វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល (GGGI) | HEAT International (HEAT) | មជ្ឈមណ្ឌលថាមពលអាស៊ាន (ACE) | Energy Efficiency Services Limited (EESL) |

កិច្ចប្រជុំរៀងរាល់ខែ ដើម្បីចែករំលែកព័ត៌មានអំពីការអនុវត្តគម្រោង

**គណៈកម្មាធិការប្រឹក្សាបច្ចេកទេស**

# គុណផលប្រសិទ្ធភាពថាមពលអគារ

## កត្តាជំរុញ

*នៅក្នុងប្រទេសតំបន់អាស៊ី, មានអគារច្រើនជាង 60% ដែលនៅមិនទាន់បានសាងសង់ជាស្ថាពរទេ ដែលជាការបើកឱកាសដ៏ធំសម្រាប់ការកាត់បន្ថយកាបូន*



### កត្តានយោបាយជំរុញ

- ច្បាប់ បរិធានការស្តីពីការអភិរក្សថាមពល
- កម្មវិធីបិទផ្លាក និងការបិទស្លាកសញ្ញា – ការតម្រូវបទដ្ឋានគុណផលការប្រើប្រាស់ថាមពលអប្បបរមា (Mandatory MEPS)
- ផែនការសកម្មភាពជាតិស្តីពីការប្រែប្រួលអាកាសធាតុ
- ផែនការសកម្មភាពសីតកម្មជាតិ(NCAP)
- ច្បាប់សន្សំសំចៃថាមពលសម្រាប់អគារ(ECBC)
- ផែនការជាតិរួមចំណែកឆ្លើយតបការប្រែប្រួលអាកាសធាតុ (NDC Commitments)

### កត្តាបច្ចេកវិទ្យាជំរុញ

- ការធ្វើបច្ចុប្បន្នភាពបទដ្ឋានគុណផលការប្រើប្រាស់ថាមពលអប្បបរមាសម្រាប់បរិក្ខារ –បទដ្ឋានគុណផលគឺត្រូវបានរឹតបន្តឹងរៀងរាល់ 2ឆ្នាំម្តងសម្រាប់ម៉ាស៊ីនត្រជាក់
- ការកែលម្អសំណង់ស្ថាបត្យកម្ម៖ការរចនាត្រជាក់អកម្ម ( Passive Cooling), ប្រព័ន្ធគ្រប់គ្រងថាមពលក្នុងអគារ (EMS)
- សម្ភារៈសំណង់កាបូនទាប
- បច្ចេកវិទ្យាថ្មី៖ សារធាតុត្រជាក់ LGWP, ត្រៃផលិតកម្មថាមពល (Tri-generation), ប្រព័ន្ធត្រជាក់ក្នុងតំបន់(District Cooling System)

### កត្តាទីផ្សារជំរុញ

- ការទទួលស្គាល់សាធារណៈតាមរយៈវិញ្ញាបនបត្រពណ៌បៃតង៖ LEED, GRIHA, IGBC, GEM និងផ្សេងៗទៀត
- ការកើនឡើងនូវតម្រូវការថាមពលសម្រាប់ស្ថាប័ន និងពាណិជ្ជកម្មក្នុងស្រុក
- កម្មវិធីការគ្រប់គ្រងតម្រូវការថាមពល (DSM) និង ការឆ្លើយតបតាមតម្រូវការ (DR) ដោយក្រុមហ៊ុនផ្គត់ផ្គង់ថាមពល
- ការទិញចូលច្រើន ដើម្បីទាញយកអត្ថប្រយោជន៍ពីសេដ្ឋកិច្ចលើអត្រាបញ្ចុះថ្លៃ
- ការយល់ដឹងរបស់អតិថិជនអំពីផលិតផលដែលមានប្រសិទ្ធភាពថាមពល និងការកើនឡើងនៃប្រាក់ចំណូលមធ្យមក្នុងមនុស្សម្នាក់

# គម្រោង ALCBT

## ចំណុចផ្តោតរបស់គម្រោង

- រៀបចំបង្កើតឧបករណ៍បច្ចេកទេស ផែនការ និងការរៀបចំស្ថាប័នសម្រាប់អគារកាបូនទាប សម្រាប់អ្នកពាក់ព័ន្ធក្នុងវិស័យសាធារណៈ និងឯកជន (រួមមានរាជរដ្ឋាភិបាល រដ្ឋបាលខេត្ត/ក្រុង អ្នកអភិវឌ្ឍន៍ ម្ចាស់អគារ អ្នកផ្គត់ផ្គង់ វិស្វករ និងស្ថាបត្យករ វិទ្យាស្ថានអភិវឌ្ឍន៍ពហុភាគី និងទ្វេភាគី ស្ថាប័នសេវាកម្មហិរញ្ញវត្ថុដូចជា ក្រុមហ៊ុនផ្តល់សេវាដំណោះស្រាយថាមពល (អេស្កូ) និង ធនាគារ។
- រៀបចំបង្កើតឧបករណ៍ស្តង់ដារ និងប្រព័ន្ធសម្រាប់គ្រប់គ្រងការបញ្ចេញកាបូនពីវិស័យអគារ និងការសាកល្បងនៅក្នុងប្រទេសអនុវត្តគម្រោង។
- ការកសាងសមត្ថភាពសម្រាប់អ្នកអនុវត្តន៍ក្នុងឧស្សាហកម្មសំណង់នាពេលបច្ចុប្បន្ន និង អនាគត។
- រៀបចំបង្កើតយន្តការហិរញ្ញវត្ថុសម្រាប់អគារដែលបញ្ចេញកាបូនទាប។
- បង្កើតតម្រូវការទីផ្សារ និងលើកកម្ពស់ការពង្រីកការអនុវត្ត។




គោលបំណងនៃគម្រោង ALCBT

# គម្រោង ALCBT

## បរិយាយហេតុផលដែលត្រូវផ្តោតលើវិស័យសំណង់អគារ

- ផ្ទៃក្រឡាសរុបនៃអគារត្រូវបានប៉ាន់ប្រមាណថានឹងកើនឡើងទ្វេដងនៅឆ្នាំ 2060 ជាមួយនឹងជាង 50% នៃការកើនឡើងនោះទំនងជានឹងកើតឡើងក្នុងរយៈពេល 20 ឆ្នាំខាងមុខ ភាគច្រើននៅអាស៊ី និងអាហ្វ្រិក
- ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីអគារ គឺជាកត្តាសំខាន់មួយនៅក្នុងការបញ្ចេញឧស្ម័នរបស់ជាតិ។ ការកើនឡើងនៃតម្រូវការថាមពលត្រជាក់ ជាហេតុធ្វើអោយមានការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ច្រើន
- នៅតំបន់អាស៊ី ថាមពលដែលបានប្រើប្រាស់នៅក្នុងអគារ មានចំនួន 49%នៃថាមពលសរុបនៅក្នុងប្រទេសចិន 25%នៅក្នុងប្រទេសឥណ្ឌា និង 23%នៅក្នុងតំបន់អាស៊ាន នៃបណ្តាប្រទេសអាស៊ានដែលមានការរីកចម្រើនយ៉ាងឆាប់រហ័ស
- កំណើនសំណង់ដែលបានព្យាករណ៍ជំរុញឱ្យមានការបញ្ចេញឧស្ម័នដែលបង្កប់ក្នុងសម្ភារៈសំណង់ផងដែរ។ កាបូនដែលបានបញ្ចូលក្នុងសម្ភារៈសំណង់មានប្រហែល 10% ការបំភាយឧស្ម័នផ្ទះកញ្ចក់សកលទាក់ទងនឹងថាមពល និងប្រហែល 20-25% នៃការបំភាយមួយវដ្តជីវិតអគារ។
- គម្រោង ALCBT ផ្តោតសំខាន់លើការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ ដោយជំរុញការផ្លាស់ប្តូរទូទាំងប្រទេសឆ្ពោះទៅរកអគារកាបូនទាបនៅក្នុងបណ្តាប្រទេសដូចជា កម្ពុជា ឥណ្ឌា ឥណ្ឌូនេស៊ី ថៃ និងវៀតណាម។




គោលបំណងនៃគម្រោង ALCBT

# គម្រោង ALCBT

## លទ្ធផលគម្រោង

**លទ្ធផល**
ឧបករណ៍បច្ចេកទេស ផែនការ និងស្ថាប័នសម្រាប់អគារកាបូនទាប ត្រូវបានអនុវត្តដោយជោគជ័យ និងអនុវត្តដោយភាគីពាក់ព័ន្ធសំខាន់ៗទាំងសាធារណៈ និងឯកជន ដែលនាំឱ្យមានការកាត់បន្ថយការបំភាយឧស្ម័នដោយផ្ទាល់។

**7** — ចំនួន និងការពិពណ៌នាអំពីអង្គភាពវិស័យឯកជន និងសាធារណៈក្នុងបណ្តាប្រទេសអនុវត្តន៍គម្រោង ដែលបានបញ្ចូលឧបករណ៍ និងកម្មវិធីបណ្តុះបណ្តាលនៃគម្រោង ALCBT ដើម្បីបញ្ជ្រាបអគារកាបូនទាបឱ្យបានទូលំទូលាយត្រឹមត្រីមាសទី ២ ឆ្នាំ ២០២៨ ។

- វិទ្យាស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈអាជីព (1)
- អ្នកអភិវឌ្ឍន៍គម្រោងអគារ (1)
- រដ្ឋបាលថ្នាក់ក្រោមជាតិ (0)
- ទីប្រឹក្សា ESCO/FI/MRV (0)
- វិទ្យាស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈសាធារណៈ (៥)

**0** — ចំនួន និងការពិពណ៌នាអំពីអនុសាសន៍គោលនយោបាយសម្រាប់ការបង្កើនប្រសិទ្ធភាពថាមពល និងការលើកកម្ពស់អគារកាបូនទាប ដែលត្រូវបានអនុម័តដោយរដ្ឋាភិបាលដៃគូ រួមទាំងការពង្រឹង NDC នៅត្រឹមត្រីមាសទី ២ ឆ្នាំ ២០២៨ ។

- គោលដៅសម្រាប់ការកាត់បន្ថយកាបូន (0)
- ការកែលម្អក្រមអគារ (0)

**140** — ចំនួនមូលនិធិ (លានអឺរ៉ូ) ដែលត្រូវបានបញ្ចេញសម្រាប់អនុវត្តវិធានការអគារកាបូនទាប តាមរយៈការប្រើប្រាស់ប្រព័ន្ធចាត់ថ្នាក់, ប្រព័ន្ធវាស់ស្ទង់ រាយការណ៍ និងការផ្ទៀងផ្ទាត់ ឬក្រុមហ៊ុនផ្តល់សេវាដំណោះស្រាយថាមពល (អេស្កូ)ដល់ត្រឹមត្រីមាសទី ២ ឆ្នាំ ២០២៨ ។

- វិធានការសំណង់កាបូនទាប និងប្រសិទ្ធភាពថាមពលសម្រាប់អគារ LC/EE (100)
- សំណើសម្រាប់មូលនិធិអាកាសធាតុ (20)
- អេស្កូតាមរយៈ Public/Pvt Finance (10)
- ការពង្រីកការអនុវត្តនិងចម្លងតាម (10)

**1.68** — ចំនួនការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ (Mn TCO2 eq) កាត់បន្ថយដោយផ្ទាល់ ឬដោយប្រយោលតាមរយៈវិធានការផ្សេងៗរបស់គម្រោង ALCBT ប្រើសម្ភារៈកាបូនទាប និងឧបករណ៍វិភាគ ដោយអ្នកជំនាញក្នុងវិស័យសំណង់ត្រឹមត្រីមាសទី ២ ឆ្នាំ ២០២៨ ។

- ការបំភាយដោយផ្ទាល់ (0.39)
- ការបំភាយដោយមិនផ្ទាល់ (1.29)

រួមបញ្ចូលគ្នាសម្រាប់ប្រទេសទាំង៥

# ការប្រែប្រួលអាកាសធាតុ

ផលប៉ះពាល់៖ ពិភពលោក អាស៊ីអាគ្នេយ៍ និងឥណ្ឌា



# ការប្រែប្រួលអាកាសធាតុ

## សីតុណ្ហភាពកើនឡើង ១,២ °C ចាប់តាំងពីចុងសតវត្សទី១៩




៩ ឆ្នាំចុងក្រោយដែលក្តៅបំផុតនៅក្នុងកំណត់ត្រា
ភាពមិនធម្មតានៃសីតុណ្ហភាពសកល (°C ធៀបនឹងមធ្យមភាគឆ្នាំ 1951-1980 )

*ប្រភព : https://earthobservatory.nasa.gov/world-of-change/global-temperatures*

# ការប្រែប្រួលអាកាសធាតុ

## ការកើនឡើងនៃការបំភាយឧស្ម័នផ្ទះកញ្ចក់ និងផលវិបាក

**មូលហេតុ៖**

- ការដុតឥន្ធនៈហ្វូស៊ីល
- ការកាប់បំផ្លាញព្រៃឈើ
- ការអនុវត្តឧស្សាហកម្ម

**ផលវិបាក៖**

- ហេតុការណ៍ធាតុអាកាសអាក្រក់ខ្លាំង
- ការផ្លាស់ប្តូរបរិស្ថាន
- រលកកម្តៅ និងគ្រោះធាតុអាក្រក់ខ្លាំង

*របាយការណ៍របស់អង្គការឧតុនិយមពិភពលោក (WMO) បានបញ្ជាក់ថា ឆ្នាំ 2023 គឺជាឆ្នាំដែលក្តៅបំផុតក្នុងកំណត់ត្រា ជាមួយនឹងសីតុណ្ហភាពជាមធ្យមជុំវិញផ្ទៃផែនដីគឺ 1.45°C (ដោយមានចំណុចមិនច្បាស់ចន្លោះ ± 0.12°C) លើសពីកម្រិតទិន្នន័យគោលមុនបដិវត្តឧស្សាហកម្ម។*



# ការប្រែប្រួលអាកាសធាតុ

## គ្រោះថ្នាក់

- ភាវរស់លើដី និងក្នុងមហាសមុទ្រកំពុងរងផលប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុ
- ការឡើងកម្តៅជាមធ្យម 1.5°C នៅទូទាំងពិភពលោកបង្កើនហានិភ័យនៃរលកកម្តៅ និងភ្លៀងធ្លាក់ខ្លាំង និងផលប៉ះពាល់ដែលអាចកើតមានជាច្រើនទៀតក្នុងចំណោមនេះ
- ដោយផ្អែកលើ 'រឿងដែលអាចកើតឡើង ដែលបានកំណត់ដោយ IPCC ដោយមានម៉ូដែលសេណារីយ៉ូពីរដែលមានការកើនឡើង សីតុណ្ហភាព 1.5°C និង 2°C ដូចដែលបានបង្ហាញជារូបភាព




*ប្រភព : https://www.ipcc.ch/site/assets/uploads/sites/2/2022/06/SR15_Chapter_3_HR.pdf*

# ការប្រែប្រួលអាកាសធាតុ

## ការប្រឈមមុខជាមួយនឹងហានិភ័យ

- ក្រុមប្រឹក្សាអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ(IPCC ) បានសង្កត់ធ្ងន់លើការវាយតម្លៃហានិភ័យ ដោយប្រើឧបករណ៍ Multi-sector risk assessment ដែលសំខាន់សម្រាប់ការយល់ដឹងពីផលប៉ះពាល់ឱ្យបានទូលំទូលាយនៃការឡើងកម្តៅផែនដី និងការប្រែប្រួលអាកាសធាតុ។
- វិធីសាស្ត្រនេះគឺចាំបាច់សម្រាប់ការវាយតម្លៃពីរបៀបដែលហានិភ័យបង្ហាញ និងអន្តរកម្មលើវិស័យផ្សេងៗដូចជា ធនធានទឹក កសិកម្ម ប្រព័ន្ធថាមពល សុខភាព ហេដ្ឋារចនាសម្ព័ន្ធ ប្រព័ន្ធសេដ្ឋកិច្ច និងប្រព័ន្ធសង្គម។
- ផែនទីកម្តៅដែលបានបង្ហាញនៅទីនេះ គឺជាផែនទីហានិភ័យ(Multi-Sector Risk - MSR) សម្រាប់ការកើនឡើងសីតុណ្ហភាព 1.5°C។ តម្លៃនៃ MSR មានចាប់ពីលេខ 0 ដល់ 9។
- ទីតាំងដែលមានពិន្ទុលើសពី 4 ត្រូវបានចាត់ទុកថាមានហានិភ័យដោយសារការឡើងកម្តៅផែនដី។
- ប្រទេសឥណ្ឌាទទួលរងផលប៉ះពាល់យ៉ាងខ្លាំង ហើយកម្ពុជា វៀតណាម និងឥណ្ឌូនេស៊ីក៏ដូចគ្នាដែរ។

**ហានិភ័យពហុវិស័យ (MSR) នៅសីតុណ្ហភាពកើនឡើង**




*ប្រភព : https://www.ipcc.ch/site/assets/uploads/sites/2/2022/06/SR15_Chapter_3_HR.pdf*

# ការប្រែប្រួលអាកាសធាតុ

## ប្រទេសឥណ្ឌា៖ គ្រោះថ្នាក់ដែលអាចកើតមាន

របាយការណ៍ "ការវាយតម្លៃអំពីការប្រែប្រួលអាកាសធាតុលើតំបន់ឥណ្ឌា" ដែលត្រូវបានបោះពុម្ពផ្សាយដោយក្រសួងវិទ្យាសាស្ត្រផែនដីរបស់ប្រទេសឥណ្ឌាក្នុងឆ្នាំ 2020 បានបង្ហាញពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើតំបន់អនុតំបន់ឥណ្ឌា ដែលសំខាន់ៗមានដូចខាងក្រោម៖

- សីតុណ្ហភាពជាមធ្យមរបស់ឥណ្ឌាបានកើនឡើងប្រមាណជា 0.7 អង្សាសេ ក្នុងកំឡុងឆ្នាំ 1901-2018។
- ភាពញឹកញាប់នៃការធ្លាក់ភ្លៀងខ្លាំងប្រចាំថ្ងៃ (អាំងតង់ស៊ីតេទឹកភ្លៀង> 150 មីលីម៉ែត្រក្នុងមួយថ្ងៃ) កើនឡើងប្រហែល 75% ក្នុងអំឡុងពេល 1950-2015 ។
- ភាពញឹកញាប់ និងវិសាលភាពនៃគ្រោះរាំងស្ងួតនៅទូទាំងប្រទេសឥណ្ឌាបានកើនឡើងយ៉ាងខ្លាំងក្នុងកំឡុងឆ្នាំ 1951-2015។
- ការកើនឡើងកម្ពស់ទឹកសមុទ្រនៅមហាសមុទ្រឥណ្ឌាខាងជើងបានកើតឡើងក្នុងអត្រា 3.3 មីលីម៉ែត្រក្នុងមួយឆ្នាំ ក្នុងរយៈពេលពីរទសវត្សរ៍កន្លះចុងក្រោយ (1993-2017)។
- ភាពញឹកញាប់នៃព្យុះស៊ីក្លូនធ្ងន់ធ្ងរនៅលើសមុទ្រអារ៉ាប់បានកើនឡើងក្នុងអំឡុងពេលក្រោយរដូវមូសុងក្នុងអំឡុងពេលឆ្នាំ 1998-2018។

*ប្រភព : 2020, Ministry of Earth Sciences, India, Assessment of Climate Change over the Indian Region*




**ប្រទេសឥណ្ឌា Cooling Degree Day ឆ្នាំ ១៩៧០-២០២០**

*ហានិភ័យអាកាសធាតុ: Cooling Degree Day (CDD) គឺជាវិធីវាស់ស្ទង់មួយដែលត្រូវបានបង្កើតឡើងដើម្បីតាមដានការប្រើប្រាស់ថាមពលសម្រាប់បញ្ចុះសីតុណ្ហភាពឱ្យត្រជាក់។ វាបានកំណត់ចំនួនអង្សាសីតុណ្ហភាពដែលលើសពី 18ºC (65ºF) នៃសីតុណ្ហភាពមធ្យមប្រចាំថ្ងៃ។ ចំនួនអង្សាទាំងនេះត្រូវបានបូកសរុបប្រចាំថ្ងៃ ដើម្បីទទួលបានតម្លៃប្រចាំឆ្នាំ។*

*ប្រភព : World Bank, Climate Change Knowledge Portal. https://climateknowledgeportal.worldbank.org*

*ប្រភព : CEICDATA.COM*

# ការប្រែប្រួលអាកាសធាតុ

## ប្រទេសឥណ្ឌា៖ គ្រោះមហន្តរាយដែលអាចកើតមាន

- ការវាយតម្លៃហានិភ័យនៃការប្រឈមនឹងគ្រោះមហន្តរាយធម្មជាតិត្រូវបានបង្ហាញនៅលើមាត្រដ្ឋានចន្លោះពី 0 ដល់ 10 សម្រាប់ឆ្នាំ 2025។
- បើប្រៀបធៀបទៅនឹងមធ្យមភាគពិភពលោក ប្រទេសទាំងអស់នៅក្នុងគម្រោង ALCBT មានហានិភ័យខ្ពស់ចំពោះទឹកជំនន់ និងគ្រោះមហន្តរាយធម្មជាតិផ្សេងទៀត។

| ប្រទេស | ទឹកជំនន់ | ទឹកជំនន់ឆ្នេរសមុទ្រ | គ្រោះរាំងស្ងួត | ព្យុះស៊ីក្លូនត្រូពិច |
|---|---|---|---|---|
| កម្ពុជា | 8.7 | 3.8 | 4.2 | 1.8 |
| ឥណ្ឌា | 9.2 | 7.8 | 6.3 | 7.7 |
| ឥណ្ឌូនេស៊ី | 8.4 | 8.1 | 3.3 | 1.5 |
| ថៃ | 9.8 | 5.5 | 5.5 | 1.6 |
| វៀតណាម | 9.9 | 9.6 | 4.2 | 5.9 |
| មធ្យមពិភពលោក | 4.5 | 3.5 | 3.4 | 1.6 |

- ការប៉ះពាល់ទាប (0 – 2.99)
- ការប៉ះពាល់មធ្យម (3 – 6.99)
- ការប៉ះពាល់ខ្ពស់ (7 – 10)

*ប្រភព : https://drmkc.jrc.ec.europa.eu/inform-index/INFORM-Risk/Results-and-data*

# ការប្រែប្រួលអាកាសធាតុ

## អាស៊ីអាគ្នេយ៍៖ ការកើនឡើងតម្រូវការថាមពលត្រជាក់

ការសិក្សារបស់ IPCC បង្ហាញថាភាគច្រើននៃតំបន់អាស៊ីអាគ្នេយ៍មាន"ការកើនឡើងនៃចំនួនយប់ក្តៅ" និងអាំងតង់ស៊ីតេ និងភាពញឹកញាប់នៃរលកកម្ដៅ។ តំបន់នេះនឹងក្លាយជាតំបន់មួយដែលរងផលប៉ះពាល់ខ្លាំងបំផុតចំពោះព្រឹត្តិការណ៍រលកកម្ដៅខ្លាំង។

ក្រោមសេណារីយ៉ូការបញ្ចេញឧស្ម័នកាបូនខ្ពស់ (លើស 3°C), តំបន់អាស៊ីអាគ្នេយ៍ត្រូវបានព្យាករណ៍ថានឹងប្រឈមមុខនឹង 48ថ្ងៃ ដែលសីតុណ្ហភាពអតិបរមានៅលើដីកើនលើសពី 35°C ដែលធំជាង4ដងមុនសម័យឧស្សាហកម្ម និង មានតែ 25 ថ្ងៃ នៅសេណារីយ៉ូបញ្ចេញឧស្ម័នកាបូនទាប។

ថាមពលធ្វើឱ្យត្រជាក់នៅកន្លែងមួយ គឺជាតម្រូវការប្រើប្រាស់អគ្គិសនីកើនលឿនបំផុត។ **លំនៅដ្ឋានប្រមាណ** 60% ត្រូវបានគេព្យាករណ៍ថានឹងមានលទ្ធភាពប្រើប្រាស់ថាមពលធ្វើឱ្យត្រជាក់នៅកន្លែងមួយ (Space Cooling) ដែលនឹងបង្កើនតម្រូវការថាមពលខ្ពស់បំផុត (Peak Demand)។




*ការប្រែប្រួលពេលថ្ងៃដែលមានសីតុណ្ហភាពអតិបរមាលើសពី 35ºC, 1850-1900, 1981-2010 និង 2081-2100*

*យប់ក្តៅត្រូវបានកំណត់ដោយ IPCC ថាជាយប់ដែលសីតុណ្ហភាពអប្បបរមានឹងលើសពីភាគរយទី 90 ក្នុងចំណោមចែកចាយសីតុណ្ហភាពដែលត្រូវបានកំណត់ដោយទូទៅយោងទៅលើរយៈពេលចន្លោះពីឆ្នាំ 1961-1990។*

*ឯកសារយោង : July 2024, IEA, Climate Resilience for Energy Security in Southeast Asia*

# សេណារីយ៉ូថាមពល

## ក្នុងតំបន់អាស៊ាន និងឥណ្ឌា



# សេណារីយ៉ូថាមពល

## តំបន់អាស៊ាន៖ កំណើនសេដ្ឋកិច្ច និងតម្រូវការថាមពល

តំបន់អាស៊ីអាគ្នេយ៍មាន ចំនួនប្រជាជន *9% នៃប្រជាជនពិភពលោក , GDP 6% នៃ GDP ពិភពលោក, នឹងប្រើប្រាស់ថាមពល 4% នៃថាមពលសរុបពិភពលោក។*

*តម្រូវការថាមពលនៅតំបន់អាស៊ាន គ្រោងថានឹងត្រូវកើនឡើងបីដង* ក្នុងឆ្នាំ 2050 ដោយប្រៀបធៀបទៅនឹងឆ្នាំ 2020។

**ផ្នែកដែលមានសក្តានុពលរីកចម្រើនក្នុងប្រទេសសមាជិកអាស៊ាន**



ហេដ្ឋារចនាសម្ព័ន្ធ | ផលិតកម្មបច្ចេកវិទ្យាខ្ពស់ | រថយន្តអគ្គិសនី | តម្រូវការថាមពលនៃវណ្ណៈកណ្តាលដែលកំពុងកើនឡើង




*ចំនួនប្រជាជននៃប្រទេសសមាជិកអាស៊ាន (AMS) ឆ្នាំ ២០០៥-២០៥០*




*តម្រូវការថាមពលឥន្ធនៈ និងផលិតផលក្នុងស្រុកសរុបក្នុងអាស៊ាន ឆ្នាំ ២០២០-២០៥០*

*ឯកសារយោង : 2022, ASEAN Center of Energy, ASEAN 7th Energy Outlook 2020-2050*

# ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីវិស័យថាមពល

## តំបន់អាស៊ាន៖ ការបំភាយឧស្ម័នដែលត្រូវបានព្យាករណ៍

នៅឆ្នាំ 2050 ការបំភាយឧស្ម័នកាបូនិក ($CO_2$) សរុបពីអាស៊ានត្រូវបានគេរំពឹងថានឹងកើនឡើងទ្វេដងពីកម្រិតឆ្នាំ 2022 ដែលភាគច្រើនមកពីវិស័យដឹកជញ្ជូន ថាមពល និងឧស្សាហកម្ម។

**នគរូបនីយកម្ម និងការប្រើប្រាស់យានយន្តគឺជាកត្តាជំរុញដ៏សំខាន់ចំពោះតម្រូវការថាមពលរបស់មនុស្សម្នាក់ៗ។**

ការប្រើប្រាស់អគ្គិសនីសរុបចុងក្រោយ(TFEC) សម្រាប់មនុស្សម្នាក់កើនឡើង 35% នៅឆ្នាំ 2030 និង 210% នៅឆ្នាំ 2050 នៅក្នុងសេណារីយ៉ូថាមពលដែលបានព្យាករណ៍ បើប្រៀបធៀបទៅនឹងឆ្នាំ 2018។

ជាមួយនឹងគោលនយោបាយត្រឹមត្រូវ និងផ្នែកហិរញ្ញវត្ថុ ការកាត់បន្ថយ 75% អាចសម្រេចបាន។

ថាមពលក្នុងមនុស្សម្នាក់ (MtCO2)




ការបញ្ចេញឧស្ម័នពីវិស័យថាមពលតាមវិស័យ ($MtCO_2$)

PES៖ សេណារីយ៉ូថាមពលដែលបានព្យាករណ៍1.5-S: សេណារីយ៉ូ 1.5 ដឺក្រេ




**ការព្យាករណ៍សម្រាប់ការបំភាយវិស័យថាមពលនៅក្នុង PES និង 1.5°C**

PES: PES គឺតំណាងឲ្យផែនការបច្ចុប្បន្ន និងគោលដៅឬគោលនយោបាយផ្សេងៗដែលបានអនុម័តនៅពេលធ្វើការវិភាគសម្រាប់របាយការណ៍នេះ។ សេណារីយ៉ូនៃការផ្លាស់ប្តូរកង្វះខាតថាមពល ត្រូវបានរៀបចំដោយ IRENA ដោយផ្អែកលើ PES។ 1.5-S: នេះគឺជាផ្លូវការផ្លាស់ប្តូរថាមពលដែលមានកំរិតសន្ទុះខ្ពស់ជាង និងបង្ហាញជម្រើសក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័ន $CO_2$ ក្នុងវិស័យដែលមានឧបសគ្គ។ វាពឹងផ្អែកយ៉ាងខ្លាំងលើសេណារីយ៉ូ World Energy Transitions Outlook (WETO) ដែលមានគោលដៅឈានដល់ការបញ្ចេញឧស្ម័នសូន្យជាសកលនៅឆ្នាំ 2050។

*ឯកសារយោង : 2022, IRENA, Renewable Energy Outlook for ASEAN: Towards a Regional Energy Transition*

# ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីវិស័យថាមពល

## ប្រទេសឥណ្ឌា៖ កំណើនសេដ្ឋកិច្ច និងតម្រូវការថាមពល

- ➢ ប្រទេសឥណ្ឌាគឺជាមហាអំណាចសេដ្ឋកិច្ចទី 5 (854.7 ពាន់លានដុល្លារគិតនៅចុងខែមីនា 2022 និងលើសចក្រភពអង់គ្លេសដែលមានចំនួន 816 ពាន់លានដុល្លារ)។
- ➢ ឥណ្ឌាគឺជាប្រទេសផលិតអគ្គិសនីធំជាងគេទី3 (1,423 TWh) និងមានអនុភាពតម្លើងធំជាងគេទី3ដូចគ្នា (429.96 GW ត្រឹមខែមករា 2024)។
- ➢ ចំនួនប្រជាជនឥណ្ឌាបានកើនលើសប្រជាជនចិនក្នុងឆ្នាំ 2022 និងមានប្រជាជនចំនួន 1.44 ពាន់លាននាក់។
- ➢ របាយការណ៍ទស្សនវិស័យចំនួនប្រជាជនពិភពលោករបស់អង្គការសហប្រជាជាតិឆ្នាំ 2024 ព្យាករណ៍ថា ឥណ្ឌានឹងឡើងដល់កំពូលចំនួន 1.7 ពាន់លាននាក់នៅដើមឆ្នាំ 2060 ឥណ្ឌានឹងនៅតែជាប្រទេសដែលមានប្រជាជនច្រើនជាងគេលើពិភពលោកក្នុងសតវត្សទី 21 ។
- ជាប្រវត្តិសាស្ត្រ ដូចដែលបានឃើញការកើនឡើងនៃផលិតផលក្នុងស្រុកសរុបបានបណ្តាលឱ្យមានការកើនឡើងនៃការប្រើប្រាស់ថាមពលក្នុងមនុស្សម្នាក់ៗ។
- តម្រូវការថាមពលរបស់ប្រទេសឥណ្ឌានឹងកើនឡើងទ្វេដងនៅឆ្នាំ 2050 ហើយនៅពឹងផ្អែកលើការប្រើប្រាស់ប្រេងឥន្ទនៈហ្វូស៊ីល រួមទាំងការនាំចូលផងដែរ។

*ប្រភព : Bloomberg Report, Statista and UN Report*




ផលិតផលក្នុងស្រុកសរុប និង ថាមពលដែលត្រូវបានប្រើប្រាស់សរុបសម្រាប់មនុស្សម្នាក់ក្នុងប្រទេសឥណ្ឌា

*ប្រភព : 2023, Niti Aayog, :* https://iced.niti.gov.in/energy
Petroleum Planning & Analysis Cell (PPAC)

# ថាមពល និងការបញ្ចេញកាបូន

## ឧស្សាហកម្មសំណង់ និងអគារសកល

- នៅទូទាំងពិភពលោក អគារប្រើប្រាស់ថាមពលច្រើនជាង 30%-34% នៃតម្រូវការថាមពលសរុបសម្រាប់តម្រូវការប្រតិបត្តិការ និងការផលិតសម្ភារៈសំណង់។
- នៅឆ្នាំ 2022 ការបញ្ចេញឧស្ម័ន កាបូនឌីអុកស៊ីត ($CO_2$) ពីប្រតិបត្តិការអគារនិងសំណង់ បានកើនដល់កម្រិតខ្ពស់ថ្មី គឺ 37% នៃការបញ្ចេញសរុប។




ភាគរយប្រើប្រាស់ថាមពលចុងក្រោយសរុបតាមប្រភេទអគារ (2022)




ភាគរយបញ្ចេញឧស្ម័នពីការប្រើប្រាស់ និងដំណើរការថាមពលពិភពលោក (2022)

*ប្រភព: 2024, UNEP Global Alliance for Buildings and Construction, Beyond Foundations*

# ផែនការជាតិរួមចំណែកឆ្លើយតបការប្រែប្រួលអាកាសធាតុ( NDC)

សន្និសីទភាគី (COP) ការសន្យា និងកាតព្វកិច្ច



# ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់

## ផែនការសកម្មភាពសម្រាប់ការកាត់បន្ថយ និងការបន្សាំ

### ការកាត់បន្ថយ

ប្រទេស 153 ឈានជិតដល់គោលដៅ Net Zero NDCs ត្រូវពង្រឹងចំណុចដៅជាបន្ទាន់ពន្លឿនសកម្មភាពពាក់ព័ន្ធនឹងធ្យូងថ្ម ការកាប់បំផ្លាញព្រៃឈើ ,រថយន្តអគ្គិសនី និងឧស្ម័នមេតាន។

### ការបន្សាំ

បានជំរុញកិច្ចខិតខំប្រឹងប្រែងដើម្បីដោះស្រាយផលប៉ះពាល់អាកាសធាតុ គាំទ្រប្រទេសដែលងាយរងគ្រោះក្នុងការបន្សាំ និងកាត់បន្ថយការបាត់បង់ និងការខូចខាតជាអប្បបរមា ។

### ហិរញ្ញវត្ថុ

កៀរគរថវិកាពាប់លានពីវិស័យសាធារណៈ និងរាប់ទ្រីលានដុល្លាពីវិស័យឯកជន

### កិច្ចសហការ

ប្រទេសជាង 40 បានគាំទ្ររបៀបវារៈនៃដំណើរការ (*Breakthrough Agenda*)

*ប្រភព : 2022, IEA, South Asia Energy Outlook*

# ការសន្យាជាសាកល

## សន្និសីទភាគី (COP)

- **អនុសញ្ញាក្របខ័ណ្ឌអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC)**
- COP គឺជាសន្និសីទភាគីអ្នកសម្រេចចិត្តដ៏សំខាន់បំផុតរបស់UNFCCC
- សន្និសីទ COP 28 ត្រូវបានរៀបចំឡើងនៅប្រទេសអារ៉ាប់រួម (UAE) ក្នុងខែធ្នូ ឆ្នាំ 2023




- **COP 3, Kyoto Protocol:** ប្រទេសឧស្សាហកម្មចំនួន 37 និងសហភាពអឺរ៉ុប (EU) បានប្តេជ្ញាកាត់បន្ថយការបំភាយឧស្ម័នរបស់ពួកគេចំនួន 5% ពីទិន្នន័យគោលឆ្នាំ 1990។
- **COP 26, Global Methane Pledge:** រួមគ្នាកាត់បន្ថយការបំភាយឧស្ម័នមេតាន 30% ពីទិន្នន័យគោល 2020 ត្រឹមឆ្នាំ 2030។
- COP 28៖ កំណត់គោលដៅដើម្បីបង្កើនភាគរយនៃថាមពលកកើតឡើងវិញបីដងក្នុងការផ្គត់ផ្គង់ថាមពល និងបង្កើនប្រសិទ្ធភាពថាមពលទ្វេដងនៃអត្រាប្រចាំឆ្នាំពី 2% ទៅ 4% នៅឆ្នាំ 2030។
- **COP 28, Global Cooling Pledge:** អនុម័តដោយប្រទេសចំនួន 71; គោលដៅសកលរួមគ្នាដើម្បីកាត់បន្ថយការបំភាយឧស្ម័នដែលទាក់ទងនឹងថាមពលត្រជាក់ឱ្យបាន 68% នៅឆ្នាំ 2050 បង្កើនលទ្ធភាពទទួលបានសីតកម្មប្រកបដោយចីរភាពនៅឆ្នាំ 2030 បង្កើនប្រសិទ្ធភាព 50% ជាមធ្យមជាសកលនៃម៉ាស៊ីនត្រជាក់ថ្មី ។






*ប្រភព : https://www.globalmethanepledge.org/; https://www.cop28.com/en/global-cooling-pledge-for-cop28; https://unfccc.int/cop28/5-key-takeaways; https://unfccc.int/event/cop-3*

# ការបូកសរុបពីសន្និសីទភាគីលើកទី២៨ (COP 28 )

## សសរស្តម្ភទាំងបួន

ការទទួលស្គាល់ការសិក្សាវិទ្យាសាស្ត្រដែលបង្ហាញថាត្រូវកាត់បន្ថយ 43% ការបំភាយឧស្ម័នផ្ទះកញ្ចក់នៅត្រឹមឆ្នាំ 2030 បើធៀបនឹងកម្រិតឆ្នាំ 2019 ដើម្បីកំណត់ការឡើងកម្តៅផែនដីត្រឹម 1.5ºC។

**គណៈប្រធាន COP 28 បានកំណត់សសរស្តម្ភចំនួនបួនសម្រាប់សន្និសីទ**

- តាមដានការផ្លាស់ប្តូរថាមពលដោយយុត្តិធម៌ សមធម៌ និងសមស្រប
- ការកែសំរួលហិរញ្ញវត្ថុអាកាសធាតុ
- ផ្តោតលើមនុស្ស ជីវិត និងជីវភាពរស់នៅ
- គាំទ្រអ្វីៗគ្រប់យ៉ាងដោយរួមបញ្ចូលពេញលេញ

*ប្រភព : https://unfccc.int/topics/global-stocktake*

# កិច្ចព្រមព្រៀងអាកាសធាតុទីក្រុងប៉ារីសឆ្នាំ២០១៥

## ផែនការជាតិរួមចំណែកឆ្លើយតបការប្រែប្រួលអាកាសធាតុ (NDCs)

### COP-21, ទីក្រុងប៉ារីស (2015)

- ប្រទេសចំនួន 195 បានចុះហត្ថលេខា និង ប្រទេស 190បានផ្តល់សច្ចាប័ន
- ការពារការកើនឡើងសីតុណ្ហភាពជាមធ្យមពិភពលោកឱ្យនៅខាងក្រោម 2°C ប្រៀបធៀបទៅនឹងសីតុណ្ហភាពមុនបដិវត្តន៍ឧស្សាហកម្ម
- បន្តការខិតខំប្រឹងប្រែងដើម្បីកម្រិតការកើនឡើងសីតុណ្ហភាពត្រឹម 1.5°Cប្រៀបធៀបទៅនឹងសីតុណ្ហភាពមុនបដិវត្តន៍ឧស្សាហកម្ម

### NDCs

- ការប្តេជ្ញាចិត្តពីប្រទេសនានាចំពោះ UNFCCC ដើម្បីកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់របស់ពួកគេ ដើម្បីកាត់បន្ថយការប្រែប្រួលអាកាសធាតុ
- ធ្វើបច្ចុប្បន្នភាព NDCs រៀងរាល់ 5 ឆ្នាំម្តង និងដាក់ជូនទៅ UNFCCC




*ប្រភព: wri.org/publication/NDC-enhancement-by-2020.*

# អាស៊ាន

## សេចក្តីថ្លែងការណ៍រួមនៅសន្និសីទភាគីលើកទី២៨ (COP 28 )

ប្រទេសឥណ្ឌូនេស៊ី ថៃ វៀតណាម និងកម្ពុជា គឺជាសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន )

ចំណុចដៅក្នុងតំបន់ដែលបានលើកឡើងសម្រាប់ឆ្នាំ 2025 នៅក្នុងផែនការសកម្មភាពអាស៊ានសម្រាប់កិច្ចសហប្រតិបត្តិការថាមពល (APAEC) គឺ៖

- ការបង្កើនថាមពលកកើតឡើងវិញដល់ 23% នៃការផ្គត់ផ្គង់ថាមពលប្រតិបត្តិការសរុប និង 35% នៃអនុភាពថាមពលដែលបានដំឡើង។
- ការកាត់បន្ថយ 32% នៃដង់ស៊ីតេប្រើប្រាស់ថាមពលពីកម្រិតឆ្នាំ 2005 ។




*រូបភាព: Wikipedia*

*ប្រភព: 2024, ASEAN Centre for Energy, ASEAN Energy in 2024.*

# ការសន្យាស្ដីពីអាកាសធាតុ

## ថាមពលកកើតឡើងវិញជាសកល ប្រសិទ្ធភាពថាមពល និងប្រព័ន្ធត្រជាក់

| ឈ្មោះការសន្យា | គោលដៅ | អ្នកចុះហត្ថលេខាអាស៊ាន |
|---|---|---|
| ការសន្យាជាសកលស្ដីពីថាមពលកកើតឡើងវិញ និងប្រសិទ្ធភាពការប្រើថាមពលមាន | បង្កើនអនុភាពផលិតថាមពលកកើតឡើងវិញជាសាកលឱ្យបានបីដងយ៉ាងហោចណាស់ដល់ 11000 GW នៅឆ្នាំ 2030 និងបង្កើនប្រសិទ្ធភាពថាមពលសកលទ្វេដងជាមធ្យមប្រចាំឆ្នាំពីប្រហែល 2% ទៅជាង 4% ក្នុងមួយឆ្នាំត្រឹមឆ្នាំ 2030។ | ប្រ៊ុយណេ ម៉ាឡេស៊ី សិង្ហបុរី និងថៃ |
| ប្រកាសសកលស្ដីពីប្រព័ន្ធត្រជាក់ | ត្រឹមឆ្នាំ 2050 កាត់បន្ថយ68% ការបំភាយឧស្ម័នដែលពាក់ព័ន្ធនឹងសីតកម្មយ៉ាងតិចធៀបនឹងឆ្នាំ 2022 ។ | ប្រ៊ុយណេ កម្ពុជា សិង្ហបុរី ថៃ និងវៀតណាម |
| សេចក្ដីប្រកាសស្ដីពីអ៊ីដ្រូសែន និងនិស្សន្ទវត្ថុ | ការទទួលស្គាល់ទៅវិញទៅមកនៃវិញ្ញាបនប័ត្រថាមពលកកើតឡើងវិញនិងអ៊ីដ្រូសែន។ | ម៉ាឡេស៊ី និងសិង្ហបុរី |

*ប្រភព: 2024, ASEAN Centre for Energy, ASEAN Energy in 2024.*

# ផែនការជាតិរួមចំណែកឆ្លើយតបការប្រែប្រួលអាកាសធាតុ NDCs

## កម្ពុជា ឥណ្ឌា ឥណ្ឌូនេស៊ី ថៃ វៀតណាម

### កម្ពុជា

- NDC-2021: គោលដៅកាត់បន្ថយ 41.7% ធៀបនឹងសេណារីយ៉ូ BAU ត្រឹមឆ្នាំ 2030
- ការកាត់បន្ថយ (វិស័យព្រៃឈើ និងការប្រើប្រាស់ដី, ថាមពល, កសិកម្ម, ឧស្សាហកម្ម និងសំណល់): USD 5.8 ពាន់លាន
- ការបន្សាំ (វិស័យហេដ្ឋារចនាសម្ព័ន្ធ, ទឹក និងកសិកម្ម): USD 2 ពាន់លាន
- យុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលវែងប្រកបដោយអព្យាក្រឹតកាបូន (2050)

### ឥណ្ឌា

- NDC 2021៖ "Panchamrit"
- ការបង្កើនអនុភាពថាមពលមិនមែនហ្វូស៊ីលដល់ 500 GW នៅឆ្នាំ 2030
- បំពេញតម្រូវការថាមពល 50% ពីថាមពលកកើតឡើងវិញនៅឆ្នាំ 2030
- កាត់បន្ថយការបំភាយកាបូនសរុបដែលបានព្យាករណ៍ចំនួន 1 ពាន់លានតោននៅឆ្នាំ 2030
- កាត់បន្ថយអាំងតង់ស៊ីតេកាបូននៃសេដ្ឋកិច្ចឱ្យតិចជាង 45% នៅឆ្នាំ 2030 ធៀបនឹងកម្រិត 2005
- សម្រេចបានគោលដៅនៃការបំភាយឧស្ម័នកម្រិតសូន្យនៅត្រឹមឆ្នាំ 2070

### ឥណ្ឌូនេស៊ី

- NDC-2022៖ កាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ 29% (ដោយគ្មានលក្ខខណ្ឌ) ការកាត់បន្ថយ 41% នៃការបំភាយ GHG (មានលក្ខខណ្ឌ) ធៀបនឹងសេណារីយ៉ូ BAU
- យុទ្ធសាស្ត្រធន់នឹងអាកាសធាតុ និងកាបូនទាបរយៈពេលវែង (LTS-LCCR) 2050
- ការបំភាយកម្រិតសូន្យនៅឆ្នាំ 2060
- វិស័យថាមពល កាកសំណល់ IPPU, AFOLU

### ថៃ

- NDC-2022៖ កាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ 30% (ដោយគ្មានលក្ខខណ្ឌ) កាត់បន្ថយ 40% នៃការបំភាយ GHG (តាមលក្ខខណ្ឌ) ធៀបនឹងសេណារីយ៉ូ BAU
- វិស័យថាមពល ដំណើរការឧស្សាហកម្ម និងការប្រើប្រាស់ផលិតផល កសិកម្ម និងវិស័យកាកសំណល់
- យុទ្ធសាស្ត្រអភិវឌ្ឍន៍ការបំភាយឧស្ម័នទាបរយៈពេលវែង (LT-LEDS)
- អព្យាក្រឹតភាពកាបូននៅឆ្នាំ 2050 និងបំភាយកម្រិតសូន្យនៅឆ្នាំ 2065

### វៀតណាម

- NDC-2022៖ ការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ 9% (ដោយគ្មានលក្ខខណ្ឌ) ការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ 27% (តាមលក្ខខណ្ឌ) ) ធៀបនឹងសេណារីយ៉ូ BAU ពីកម្រិតឆ្នាំ 2014
- វិស័យថាមពល កសិកម្ម ការប្រើប្រាស់ដី ការផ្លាស់ប្តូរការប្រើប្រាស់ដី និងព្រៃឈើ និងដំណើរការឧស្សាហកម្ម និងផលិតផល
- ផែនការសម្រាប់ការអនុវត្តកិច្ចព្រមព្រៀងទីក្រុងប៉ារីស (PIPA) ក្នុងឆ្នាំ 2016 ដែលមានគោលបំណងចំនួន 68 ទាក់ទងនឹងការកាត់បន្ថយ ការបន្សាំ ធនធានមនុស្ស បច្ចេកទេស និងហិរញ្ញវត្ថុ និង MRV
- ការបំភាយឧស្ម័នកម្រិតសូន្យត្រឹមឆ្នាំ 2050

*ប្រភព : https://ndcpartnership.org/*

# NDCs ស្ដីពីវិស័យអគារ

## កម្ពុជា ឥណ្ឌា ឥណ្ឌូនេស៊ី ថៃ វៀតណាម

### កម្ពុជា

- ក្រមអគារ, ការអនុវត្ត/វិញ្ញាបនប័ត្រ សម្រាប់អគារថ្មី ដើម្បីបន្ថយការប្រើប្រាស់អគ្គិសនី 10% ក្នុងឆ្នាំ 2030។
- ការបង្កើនប្រសិទ្ធភាពប្រព័ន្ធត្រជាក់នៅអគារសាធារណៈ ដើម្បីបន្ថយការបញ្ចេញកាបូនឌីអុកស៊ីតចុះ 43,000 តោនក្នុងមួយឆ្នាំ។
- ការប្រើប្រាស់ប្រព័ន្ធត្រជាក់ដោយធម្មជាតិក្នុងអគារ ដើម្បីបន្ថយ 74.5 តោន CO2e។

### ឥណ្ឌា

- ប្រសិទ្ធភាពថាមពល និងសម្ភារៈនៅក្នុងអគារ និងបង្កើនភាពធន់នឹងអាកាសធាតុនៃទីក្រុង
- គំនិតផ្តួចផ្តើមទីក្រុងឆ្លាតវៃ ការធ្វើផែនការរួមនៃទីក្រុងសម្រាប់ការបញ្ជ្រាបការបន្សាំ និងការបង្កើនប្រសិទ្ធភាពថាមពល និងធនធាន ក្រមអគារបៃតងប្រកបដោយប្រសិទ្ធភាព និងការអភិវឌ្ឍន៍យ៉ាងឆាប់រហ័សក្នុងការគ្រប់គ្រងកាកសំណល់រឹង និងរាវប្រកបដោយភាពច្នៃប្រឌិត។

### ឥណ្ឌូនេស៊ី

- បញ្ចូលការប្រើប្រាស់ប្រសិទ្ធភាពថាមពលក្នុងអគារ តាមរយៈការអនុវត្តក្រមអគារបៃតងសម្រាប់អគារថ្មី និងអគារមានស្រាប់។
- ការផ្សព្វផ្សាយការប្រើប្រាស់បរិក្ខារថាមពលមានប្រសិទ្ធភាព និងប្រព័ន្ធបំភ្លឺក្នុងអគារ។
- បង្កើនល្បាយស៊ីម៉ង់ដោយបង្កើនភាគរយនៃវត្ថុធាតុជំនួស ដើម្បីកាត់បន្ថយសមាមាត្រគ្លីនឃ័រ ទៅស៊ីម៉ង់(Clinker to Cement Ratio)។
- ការផ្សារភ្ជាប់ការអភិវឌ្ឍន៍ទីក្រុងដែលអាចធន់នឹងអាកាសធាតុ ដើម្បីធានាការប្រកបដោយចីរភាព។

### ថៃ

- ការអនុវត្តផែនការប្រើប្រាស់ថាមពលប្រសិទ្ធភាពជាតិ B.E. 2558-2579 ( 2015-2036 ) ផែនការនេះមានគោលដៅកាត់បន្ថយតម្រូវការថាមពលចុះ 30% ដល់ឆ្នាំ 2036 បើប្រៀបធៀបទៅនឹងសេណារីយ៉ូ BAU។

### វៀតណាម

- ការជំនួសសម្ភារៈសំណង់ និងការកែលម្អដំណើរការផលិតស៊ីម៉ង់ និងគីមី
- កាត់បន្ថយការប្រើប្រាស់ Hydrofluorocarbons (HFCs) ដោយអនុវត្តដំណើរការផលិតប្រសើរឡើង។
- កែលម្អ, អភិវឌ្ឍ និងអនុវត្តបច្ចេកវិទ្យានៅក្នុងការផលិតសម្ភារៈសំណង់។
- បន្ថយគ្លីនឃ័រ (Clinker Content) និងអនុវត្តវិធានការផ្សេងទៀត ដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នពុលសម្រាប់ផលិតស៊ីម៉ង់។
- អភិវឌ្ឍន៍ និងប្រើប្រាស់សម្ភារៈសំណង់ដែលសន្សំថាមពល និងសម្ភារៈបៃតងសម្រាប់វិស័យសេដ្ឋកិច្ច និងសំណង់អាជីវកម្ម។

*ប្រភព : 2019, Wei Zhou et al, ADB, Accelerating Net Zero Transition in the Building Sector.*

# កម្ពុជា

## សេណារីយ៉ូថាមពល, ការបញ្ចេញឧស្ម័ន, NDCs និង BEEP



Image source:https://nowboarding.changiairport.com/travel-the-world/travel-guide-cambodia-phnom-penh.html

# កម្ពុជា៖ សេណារីយ៉ូថាមពល

## បរិមាណថាមពលបឋមផ្គត់ផ្គង់សរុប (TPES)

កំណើនតម្រូវការថាមពលច្រើនបំផុតត្រូវបានព្យាករណ៍ថាចេញពី**ការដឹកជញ្ជូន**ដែលនឹងកើនឡើង**ប្រាំដង**ក្នុងអត្រាជាមធ្យមប្រចាំឆ្នាំ 5.33% ក្នុងឆ្នាំ 2019-2050 ពី 2.09 Mtoe ដល់ 10.46 Mtoe ។

តម្រូវការថាមពលក្នុងឧស្សាហកម្មត្រូវបានព្យាករណ៍ថានឹងកើនឡើង 4.32 ដងក្នុងអត្រាប្រចាំឆ្នាំ 4.85% ពី 0.95 Mtoe ក្នុងឆ្នាំ 2019 ដល់ 4.11 Mtoe ក្នុងឆ្នាំ 2050 បន្តដោយវិស័យ "ផ្សេងទៀត" ពី 3.07% ពី 1.91 Mtoe ក្នុងឆ្នាំ 2019 ដល់ 4.80 ក្នុងឆ្នាំ 2050 ។

*បរិមាណថាមពលបឋមផ្គត់ផ្គង់សរុបរបស់កម្ពុជា ក្នុងសេណារីយ៉ូ BAU(1990-2050)*
*Fig: Cambodia Total Primary Energy Supply Business AS Usual (1990-2050)*




*បរិមាណថាមពលប្រើប្រាស់សរុបចុងក្រោយតាមវិស័យនីមួយៗ*




*ប្រភព : ERIA, Energy Outlook and Energy Saving Potential East Asia 2023*

# កម្ពុជា៖ ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ (GHG)

## ឆ្នាំ 2021

យោងតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលវែងប្រកបដោយអព្យាក្រឹតកាបូនសម្រាប់ប្រទេសកម្ពុជា វិស័យព្រៃឈើ និងការប្រើប្រាស់ដី (FOLU) ទទួលខុសត្រូវចំពោះការបំភាយឧស្ម័នចំនួន 51 MtCO2e ក្នុងឆ្នាំ 2016 ដែលជាចំណែកដ៏ធំបំផុតនៃការបំភាយឧស្ម័ននៅក្នុងប្រទេសកម្ពុជាសរុប។ ការកាប់បំផ្លាញព្រៃឈើគឺជាមូលហេតុចម្បងនៃការបំភាយឧស្ម័ន។

ឆ្នាំ ២០២០៖ ការបំភាយឧស្ម័នដ៏ធំបំផុតពី FOLU ។

BAU 2050៖ អ្នកបញ្ចេញដ៏ធំបំផុតត្រូវបានគេរំពឹងថាជាវិស័យថាមពល។




*Figure 5: GHG emissions projections in the BAU scenario by sector*

*ប្រភព: March 13, 2024, One Planet Two Realities; Realizing Energy Transition in Global South, S&P Global*

# កម្ពុជា៖ តម្រូវការថាមពល

2022-2040

យោងតាមផែនការមេនៃការអភិវឌ្ឍន៍ថាមពលរបស់កម្ពុជា (PDP) 2022-2040 តម្រូវការអគ្គិសនីខ្ពស់បំផុតរបស់ប្រទេសត្រូវបានគេរំពឹងថានឹងកើនឡើងពី 7.5-8.9% ជារៀងរាល់ឆ្នាំ។នេះនឹងបណ្តាលឱ្យមានតម្រូវការខ្ពស់បំផុតដល់ 8.9 GW នៅត្រឹមឆ្នាំ 2040

PDP ក៏បានព្យាករដែរថា នៅឆ្នាំ២០៤០ សមត្ថភាពថាមពលរបស់កម្ពុជា ៦៣% នឹងបានមកពីប្រភពកកើតឡើងវិញ ដោយ ៣២% បានមកពីថាមពលពន្លឺព្រះអាទិត្យ និង ៣០% ពីវារីអគ្គិសនី

Cambodia PDP Energy Demand Forecast (GWh/TWh)




Energy Demand Forecast (GWh) and average annual growth rates (%)

| | Actual | | Projection | | | | | Average Annual Growth Rate (%) | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| GWh | 2015 | 2019 | 2020 | 2025 | 2030 | 2035 | 2040 | 2019/2015 | 23/2019 | 2025/2019 | 2030/2019 | 2040/2019 |
| Base (without EE) | 6,144 | 11,705 | 12,290 | 24,184 | 36,465 | 50,405 | 66,187 | 17.50% | 13.90% | 12.90% | 11.5% | 8.8% |
| Base (with EE) | 6,144 | 11,705 | 12,290 | 22,108 | 30,080 | 41,579 | 54,597 | 17.50% | 9.40% | 9.50% | 9.4% | 7.7% |

*Source: Cambodia Power Development Masterplan, 2022-2040*

# ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ (GHG )

## ការបញ្ចេញឧស្ម័នរបស់កម្ពុជា ប្រៀបធៀបទៅនឹងប្រទេសនៅអាស៊ីអាគ្នេយ៍

- អត្រាការកំណើនការបញ្ចេញឧស្ម័នលឿនបំផុត; ហានិភ័យអន្តរកាល
- ជាសេដ្ឋកិច្ចដែលបញ្ចេញដង់ស៊ីតេកាបូន ច្រើនបំផុតបន្ទាប់ពីប្រទេសមីយ៉ាន់ម៉ា។
- ប្រភពនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ (GHG) ដែលកំពុងកើនលឿនបំផុតគឺ ការផលិតអគ្គិសនី និងថាមពលកម្តៅ; ប្រព័ន្ធត្រជាក់ និងការប្រើប្រាស់ក្នុងឧស្សាហកម្ម។
- វិស័យសំណង់ គឺជាមូលដ្ឋានស្នូលសំខាន់ និងជាអ្នករួមចំណែកដ៏សំខាន់ចំពោះ GDP ដែលនឹងមានឥទ្ធិពលលើការបញ្ចេញឧស្ម័នក្នុងវិស័យនេះ។

**កម្ពុជាមានការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ទាបប៉ុន្តែកើនឡើងយ៉ាងឆាប់រហ័ស**

| | GHG emissions per capita ($tCO_2e$ per person) | Carbon intensity ($tCO_2e$ per US$ million of GDP) | Total GHG emissions ($mtCO_2e$) | Annual emissions % growth rate (2010–2019) |
|---|---|---|---|---|
| United States | 17.6 | 270 | 5771 | -0.5 |
| Malaysia | 12.4 | 1081 | 396 | 0.8 |
| OECD members | 10.6 | 258 | 13797 | -0.6 |
| China | 8.6 | 844 | 12055 | 2.2 |
| Indonesia | 7.2 | 1751 | 1960 | 6.3 |
| Thailand | 6.3 | 804 | 437 | 4.4 |
| Lao | 5.5 | 2104 | 39 | 3.6 |
| Vietnam | 4.5 | 1326 | 438 | 5.2 |
| Myanmar | 4.5 | 3537 | 243 | 0.5 |
| **Cambodia** | **4.4** | **2649** | **72** | **8.2** |
| Philippines | 2.2 | 628 | 237 | 3.5 |

*Source and notes: Climate Analysis Indicators Tool. Emissions are all GHG emissions and estimates for 2019. Annual emissions growth is calculated as the compound annual growth rate.*

*ប្រភព: Cambodia, Country Climate and Development Report, World Bank, September 2023*

# ការផ្ដួចផ្ដើមរបស់កម្ពុជា

## កាលប្បវត្តិនៃគោលនយោបាយស្ដីពីអាកាសធាតុ និងថាមពល

**2001,**
បានកែប្រែក្នុងឆ្នាំ
2007, 2015

**ច្បាប់អគ្គិសនី**
ព្រះរាជក្រឹត្យ នស/រកម/
០២០១/០៣

*កំណត់តួនាទីរបស់ភាគីសំខាន់ៗក្នុងវិស័យអគ្គិសនី MME & EAC និងការពារអ្នកប្រើប្រាស់ពីការកំណត់តម្លៃផ្ដាច់មុខ*

**2004, 2008, 2013,2018**

**យុទ្ធសាស្ត្រចតុកោណកម្ពុជាសម្រាប់កំណើនសមធម៌ការងារ និងប្រសិទ្ធភាព I,II,II,IV**

*នយោបាយគោលសម្រាប់ការអភិវឌ្ឍន៍ផ្ទាត់បរិយាបននិងនិរន្តរភាព ដើម្បីកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ដោយការពង្រឹងសមត្ថភាពបន្សាំ និងភាពធន់នឹងការប្រែប្រួលអាកាសធាតុ និងរួមចំណែកដល់ការកាត់បន្ថយបំភាយឧស្ម័នផ្ទះកញ្ចក់ជាសកល*

**2009**

**ផែនការយុទ្ធសាស្ត្រជាតិអភិវឌ្ឍន៍បៃតង**

*លើកកម្ពស់ការអភិវឌ្ឍន៍ដែលមានគោលបំណងធ្វើឱ្យប្រសើរឡើងនូវភាពធន់នឹងផលប៉ះពាល់អវិជ្ជមាន ខណៈពេលដែលជ្រើសរើសជម្រើសកាបូនទាបសម្រាប់ "កំណើនបៃតង" ដើម្បីកាត់បន្ថយ និងសម្របខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ។*

**2006,2009, 2019**

**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) និងបច្ចុប្បន្នភាពរបស់វា**

*ផែនការនេះបង្ហាញពីគោលដៅអាទិភាព និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា (RGC) ក្នុងការកាត់បន្ថយភាពក្រីក្រ ដោយយុមានប្រសិទ្ធភាព និងឆាប់រហ័ស និងដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម និងគោលដៅអភិវឌ្ឍន៍សម្រាប់ប្រយោជន៍របស់ប្រជាជនកម្ពុជាទាំងអស់។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ (NSDP) មានតួនាទីជាឧបករណ៍ដឹកនាំសម្រាប់យុទ្ធសាស្ត្រចតុកោណដើម្បីសម្រេចគោលដៅដែលបានព្យាករណ៍។*

**2013**

**គោលនយោបាយជាតិ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាព ស្ដីពីប្រសិទ្ធភាពថាមពលនៅកម្ពុជា**

*ការពិភាក្សាសង្ខេបអំពីគោលនយោបាយប្រសិទ្ធភាពថាមពលដែលបានអនុវត្តថ្មីៗជាមួយនឹងផែនការ និងគោលនយោបាយអភិវឌ្ឍន៍ប្រសិទ្ធភាពថាមពលក្នុងរយៈពេលខ្លី មធ្យម និងវែងនៅក្នុងវិស័យថាមពល។ ដូចគ្នានេះផងដែរគាំទ្រដល់ការអភិវឌ្ឍន៍គោលនយោបាយប្រសិទ្ធភាពថាមពលជាតិ, យុទ្ធសាស្ត្រប្រសិទ្ធភាពថាមពលជាតិ, និងផែនការសកម្មភាពប្រសិទ្ធភាពថាមពលជាតិ។*

**2014-2023**

**ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា (CCCSP)**

*រចនាសម្ព័ន្ធជាតិមួយសម្រាប់ជំរុញការចូលរួមរបស់សាធារណជន វិស័យឯកជន អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ ដោយឆ្លើយតបប្រកបដោយការចូលរួមផ្ដល់យោបល់ក្នុងដំណើរការឆ្លើយតបចំពោះបញ្ហាអាកាសធាតុ ដើម្បីគាំទ្រការអភិវឌ្ឍដែលមានចីរភាព។*

*ប្រភព :* *UN ESCAP, https://asiapacificenergy.org/apef/index.html#main/lang/en/time/[2018,2024]/geo/[]/search*

# ការផ្តួចផ្តើមរបស់កម្ពុជា

## តារាងពេលវេលាសម្រាប់គោលនយោបាយស្តីពីអាកាសធាតុ និងថាមពល

**ការរួមចំណែករបស់ជាតិដែលបានកំណត់ (INDC)**

2016

*ឯកសារគោលនយោបាយពហុវិស័យ ក្នុង INDC កម្ពុជា បានផ្តល់ជូននូវការរួមចំណែកកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់សម្រាប់រយៈពេល 2020-2030 ដែលផ្អែកលើលក្ខខណ្ឌនៃការគាំទ្រពីសហគមន៍អន្តរជាតិ។ វិស័យសំខាន់ៗរួមមាន ថាមពល ការផលិតឧស្សាហកម្ម និងការដឹកជញ្ជូន។*

2016 - 2018

*ផែនការយុទ្ធសាស្ត្រសម្រាប់ភាគីពាក់ព័ន្ធនានា រួមទាំងអាជីវកម្ម ដើម្បីអនុវត្តសកម្មភាពដែលនឹងរួមចំណែកក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ និងឆ្ពោះទៅរកសេដ្ឋកិច្ចធន់នឹងកាបូនទាប។*

**ផែនការសកម្មភាពការប្រែប្រួលអាកាសធាតុសម្រាប់វិស័យរ៉ែ និងថាមពល**

**ផែនការថាមពលមូលដ្ឋានរបស់កម្ពុជា**

2019

*កំណត់ចំនួនគោលដៅសម្រាប់បញ្ហាថាមពលនីមួយៗដែលគ្របដណ្តប់ដោយផែនការ គោលបំណងជាមូលដ្ឋាននៃផែនការគឺស្វែងរកការផ្គត់ផ្គង់ថាមពលសម្រាប់ប្រទេសកម្ពុជាជាមួយនឹងលក្ខខណ្ឌដូចខាងក្រោម៖ តម្លៃសមរម្យ គ្រប់គ្រាន់ សន្តិសុខថាមពល (សន្តិសុខប្រកបដោយនិរន្តរភាព) សុវត្ថិភាព និងតម្លាភាពនៅក្នុងទីផ្សារថាមពល។ វាគ្របដណ្តប់លើផ្នែកមូលដ្ឋានដូចជា ប្រេង ថាមពលកកើតឡើងវិញ ប្រសិទ្ធភាពថាមពល សន្តិសុខថាមពល និងទស្សនវិស័យថាមពល*

2020

*កម្ពុជាបានបង្ហាញការប្តេជ្ញាចិត្តក្នុងការប្រយុទ្ធប្រឆាំងនឹងបញ្ហាប្រែប្រួលអាកាសធាតុ ដោយដាក់គោលដៅកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ប្រហែល 42 ភាគរយពីសេណារីយ៉ូ BAU ត្រឹមឆ្នាំ 2030។ ក្នុងចំណោមគោលដៅនេះ វិស័យថាមពលបានក្លាយជាវិស័យធំទីពីរ ដែលមានតួនាទីសំខាន់ក្នុងការជួយសម្រេចគោលដៅ។*

**បច្ចុប្បន្នភាព NDC**

**ច្បាប់សំណង់**

2019

*ច្បាប់នេះបានកំណត់គោលការណ៍សម្រាប់ក្របខណ្ឌច្បាប់នៃវិស័យសំណង់។ច្បាប់នេះបានលើកឡើងអំពីប្រសិទ្ធភាពសំណង់ និងគោលគំនិតនៃអគារបៃតងដែលធានាការអភិវឌ្ឍន៍បៃតង ការការពារធនធានធម្មជាតិ និងបរិស្ថាន ការធានាគុណភាពសំណង់ សុវត្ថិភាព និងសន្តិសុខ និងការការពារសម្បត្តិ និងសុខុមាលភាពនៃសំណង់។ក្នុងនោះ ការរួមបញ្ចូលបទដ្ឋានអប្បបរមាស្តីពីប្រសិទ្ធភាពថាមពល គឺជាភាពចាំបាច់ ដើម្បីជៀសវាងការចាក់សោនៅក្នុងបរិស្ថានដែលគ្មានប្រសិទ្ធភាព។*

*ប្រភព :* UN ESCAP, *https://asiapacificenergy.org/apef/index.html#main/lang/en/time/[2018,2024]/geo/[]/search*

# ការផ្ដួចផ្ដើមរបស់កម្ពុជា

## តារាងពេលវេលាសម្រាប់គោលនយោបាយស្ដីពីអាកាសធាតុ និងថាមពល

**2020**

**ផែនការមេស្តីពីប្រសិទ្ធភាពថាមពល និងការអភិរក្សក្នុងប្រទេសកម្ពុជា**

*ផែនការនិងគោលនយោបាយនេះមានការផ្ដោតសំខាន់លើ ៥ ចំណុច៖ 1) ក្រុមហ៊ុនផ្ដល់សេវាដំណោះស្រាយថាមពល (អេស្កូ), 2) បង្កើនចំនួនអ្នកគ្រប់គ្រងថាមពល, 3) ប្រព័ន្ធបទដ្ឋាននិងការបិទស្លាកសញ្ញា, 4) ការអប់រំ និងយុទ្ធនាការ, និង 5) ការរៀបចំសូចនាករប្រសិទ្ធភាពថាមពល។ វិស័យត្រជាក់ត្រូវបានរួមបញ្ចូលក្នុងបទដ្ឋាននិងការបិទស្លាកសញ្ញា។*

**2020**

*កម្ពុជាបានបង្ហាញការប្ដេជ្ញាចិត្តក្នុងការប្រយុទ្ធប្រឆាំងនឹងបញ្ហាប្រែប្រួលអាកាសធាតុ ដោយដាក់គោលដៅកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ប្រហែល 42 ភាគរយពីសេណារីយ៉ូ BAU មុនឆ្នាំ 2030។ ក្នុងចំណោមគោលដៅនេះ វិស័យថាមពលបានក្លាយជាវិស័យធំទីពីរ ដែលមានតួនាទីសំខាន់ក្នុងការជួយសម្រេចគោលដៅ។*

**បច្ចុប្បន្នភាពការចូលរួមចំណែករបស់ជាតិដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្ដីពីការប្រែប្រួលអាកាសធាតុ (NDC)**

**2021**

**សេចក្ដីព្រាងផែនការយុទ្ធសាស្ត្រ NDC សម្រាប់អគារនិងសំណង់ដែលមានការបន្ថយកាបូន និងភាពធន់នឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា ដោយមានចក្ខុវិស័យដល់ឆ្នាំ 2050**

*ផែនការបង្ហាញផ្លូវត្រូវបានរៀបចំឡើងដើម្បី "គាំទ្រក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (MLMUPC) និងរាជរដ្ឋាភិបាលកម្ពុជា (RGC) ក្នុងការលើកកម្ពស់គោលដៅអាកាសធាតុក្នុងវិស័យនេះឲ្យកាន់តែស៊ីជម្រៅ ស្របតាមគោលដៅ NDC របស់ប្រទេស ដែលបានធ្វើបច្ចុប្បន្នភាពដើម្បីបង្កើនគោលដៅការកាត់បន្ថយការបញ្ចេញឧស្ម័ន និងការអនុវត្តសមិទ្ធផលទូទាំងសេដ្ឋកិច្ច ត្រឹមឆ្នាំ2025" ផ្នែកគាំទ្រទាំង ៨ គឺ៖ "ផែនការទីក្រុង អគារថ្មី អគារមានស្រាប់ អគារ (ការកែលម្អឡើងវិញ) ប្រតិបត្តិការអគារ ប្រព័ន្ធ និងឧបករណ៍ សម្ភារៈ ភាពធន់ និងថាមពលស្អាត"*

**2022**

*រួមបញ្ចូលវិធានការដើម្បីកាត់បន្ថយការប្រើប្រាស់ថាមពលនៅកម្ពុជា ដោយបង្កើនប្រសិទ្ធភាពថាមពល។ វាកំណត់គោលដៅទូទាំងប្រទេសសម្រាប់ការកាត់បន្ថយការប្រើប្រាស់ថាមពល រួមជាមួយគោលដៅជាក់ស្ដែងសម្រាប់វិស័យនីមួយៗ។*

**គោលនយោបាយជាតិប្រសិទ្ធភាពថាមពល (NEEP)**

**2023**

**អនុក្រឹត្យលេខ 254 ស្ដីពីការគ្រប់គ្រង និងលើកកម្ពស់ប្រសិទ្ធភាពថាមពលបរិក្ខារអគ្គិសនី**

*តម្រូវឱ្យឧបករណ៍អគ្គិសនីមុខសញ្ញាក្នុងប្រទេសកម្ពុជាមានស្លាកសញ្ញាប្រសិទ្ធភាពថាមពល និងត្រូវតាមស្តង់ដារជាក់លាក់*

**2023**

*NCAP បានកំណត់សកម្មភាពទូលំទូលាយដើម្បីកាត់បន្ថយការប្រើប្រាស់ថាមពល និងការបញ្ចេញឧស្ម័នចេញពីប្រព័ន្ធត្រជាក់ ស្របតាមផែនការដើលទាក់ទងនឹងការផ្លាស់ប្ដូរប្រភេទឧស្ម័នត្រជាក់។ កម្ពុជា បានក្លាយជាប្រទេសដំបូងក្នុងការរៀបចំគម្រោងបង្ហាញដោយប្រើវិធីសាស្ត្រ Cool Coalition ។*

**ផែនការសកម្មភាពសីតកម្មជាតិរបស់កម្ពុជា (NCAP)**

*ប្រភព : UN ESCAP, https://asiapacificenergy.org/apef/index.html#main/lang/en/time/[2018,2024]/geo/[]/search*

# យន្តការស្ថាប័ន

## គោលនយោបាយអាកាសធាតុ៖ គណៈកម្មាធិការជាតិសម្រាប់ការអនុវត្តន៍

ក្របខណ្ឌស្ថាប័នដែលបានបង្កើតឡើងដើម្បីដឹកនាំការឆ្លើយតបនឹងអាកាសធាតុរបស់កម្ពុជា រួមមានការបង្កើតក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (NCSD) លេខាធិការដ្ឋានរបស់ខ្លួន (GSSD) (ឆ្នាំ 2015) (ព្រះរាជក្រឹត្យលេខ នស/រ./0515/403 និងអនុក្រឹត្យលេខ 59 អនុ.ណរ.បករ) និងក្រុមការងារបច្ចេកទេសការប្រែប្រួលអាកាសធាតុរបស់ក្រុមប្រឹក្សា (CCTWG) (2017) (ប្រកាសលេខ 002 S.S.R NCSD) បញ្ជាក់ពីតួនាទី និងភារកិច្ចសម្រាប់ការអភិវឌ្ឍន៍ និងការគ្រប់គ្រងឧបករណ៍តាមដាន និងវាយតម្លៃ (M&E ) ទាក់ទងនឹងការប្រែប្រួលអាកាសធាតុ និងក្របខណ្ឌ M&E ជាតិសម្រាប់ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។

### ការអនុម័តគោលនយោបាយ៖

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (NCSD)

### ការអភិវឌ្ឍន៍ និងតាមដានគោលនយោបាយ៖

1) លេខាធិការដ្ឋានរបស់ NCSD (GSSD)

2) ក្រុមការងារបច្ចេកទេសបម្រែបម្រួលអាកាសធាតុ (CCTWG)




*ប្រភព : https://ncsd.moe.gov.kh/ndc-tracking/public/NDC/*

# សកម្មភាពកាត់បន្ថយនៅក្នុង NDC

## LTS4CN ការកាត់បន្ថយ, ការបន្សាំ និងសកម្មភាពដែលអាចអនុវត្តបាន

**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលវែងប្រកបដោយអព្យាក្រឹតកាបូន (LTS4CN)** ជាផែនទីបង្ហាញផ្លូវ ឬឯកសារចក្ខុវិស័យដែលបង្ហាញពីសកម្មភាពកាត់បន្ថយជាអាទិភាពសម្រាប់វិស័យនីមួយៗ ដើម្បីសម្រេចបាននូវគោលដៅរបស់ប្រទេសដែលមានសេដ្ឋកិច្ចអព្យាក្រឹតកាបូននៅឆ្នាំ 2050 ។

### សកម្មភាពកាត់បន្ថយ

- មានចំនួន 33 បានកំណត់អាទិភាពក្នុង 7 វិស័យ
- មានចំនួន 7 សម្រាប់វិស័យសំណង់
- ការកាត់បន្ថយការបញ្ចេញឧស្ម័ន 42% ប្រៀបធៀបនឹងការព្យាករតាមទម្លាប់ធម្មតា (BAU)

### សកម្មភាពបន្សាំ:

- 58 បានកំណត់អាទិភាពក្នុង 11 វិស័យ
- 6 សម្រាប់វិស័យសំណង់
- បន្ថយភាពងាយរងគ្រោះនៃការប្រែប្រួលអាកាសធាតុ







**សកម្មភាពអនុវត្តនៅក្នុងវិស័យដែលមានឥទ្ធិពលលើឧស្សាហកម្មសំណង់ និងអគារ**

*ប្រភព : NDC (moe.gov.kh)*

*ប្រភព : https://ncsd.moe.gov.kh/ndc-tracking/public/NDC/*

# ការធ្វើបច្ចុប្បន្នភាព NDCs

## កម្ពុជានៅឆ្នាំ 2021




**វិស័យនៃLTS4CN ដែលកាត់បន្ថយ ( ប្រភព : NDC, moe.gov.kh)**

ការកាត់បន្ថយការបញ្ចេញឧស្ម័ន GHG ដល់ 42% ប្រៀបធៀបនឹងសេណារីយ៉ូ BAU ត្រឹមឆ្នាំ 2030 ( ផ្អែកលើការគាំទ្រពីសហគមន៍អន្តរជាតិ )

ការកាត់បន្ថយនៅឆ្នាំ 2030 ក្រោមសេណារីយ៉ូ BAU៖

- ព្រៃឈើ និងការប្រើប្រាស់ដីផ្សេងៗទៀត: 50%
- ថាមពល: 40%
- កសិកម្ម: 23%
- ឧស្សាហកម្ម : 42%
- សំណល់: 18%




*ការព្យាករណ៍ការបញ្ចេញឧស្ម័ន GHG, សេណារីយ៉ូ BAU និង LT4CN*

*ប្រភព : Dec 2021, Kingdom of Cambodia, Long Term Strategy for Carbon Neutrality (LTS4CN)*

# សកម្មភាពកាត់បន្ថយនៅក្នុង NDC

## សកម្មភាពសំខាន់ៗនៃការកាត់បន្ថយក្នុងវិស័យសំណង់ និងអគារ និងគោលដៅការកាត់បន្ថយត្រឹមឆ្នាំ 2030




ការផលិតឥដ្ឋ
ប្រកបដោយនិរន្តរភាព



ឧបករណ៍ទីក្រុង
សម្រាប់ UHIE




ការគ្រប់គ្រងថាមពលនៅក្នុង
ឧស្សាហកម្ម




ការយល់ដឹងជាសាធារណៈ




ការអនុវត្តនីតិវិធីសំណង់សម្រាប់អគារថ្មី
និងការជួសជុលកែលម្អ




ស្លាកសញ្ញានិងស្តង់ដារ
ប្រសិទ្ធភាពថាមពលអប្បបរមា




ប្រសិទ្ធភាពម៉ូទ័រនិង
ប្រសិទ្ធភាពឡចំហាយ




ការដាក់បញ្ចូលថាមពលកកើតឡើងវិញ ទៅក្នុងល្បាយប្រភពផលិតថាមពល ( Energy mix)



ការអនុវត្ត NCAP



ប្រព័ន្ធត្រជាក់អកម្មក្នុងក្រុមថាមពលអគារ



ការដោះស្រាយបញ្ហា
UHIE នៅក្នុងទីក្រុង

*ប្រភព : https://ndcpartnership.org/country/tha*

# NEEP

## គោលនយោបាយជាតិប្រសិទ្ធភាពថាមពល(2022–2030 )

### ចក្ខុវិស័យ

ដើម្បីកែប្រែការប្រើប្រាស់ថាមពលនៅកម្ពុជាឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ដើម្បីលើកកម្ពស់សេដ្ឋកិច្ចជាតិឱ្យរឹងមាំ រស់រវើក ប្រកួតប្រជែង និងការអភិវឌ្ឍប្រកបដោយចីរភាព។




*ប្រភព: NEEP, Royal Government of Cambodia 2022 - 2030.*

# វិស័យសំណង់

## គោលដៅជាតិ និងសសរស្តម្ភយុទ្ធសាស្ត្រ

1. កម្មវិធីស្តង់ដារ និងស្លាកសញ្ញា — 2022-23
2. កូដថាមពលអគារ — 2023-24
3. ការណែនាំសម្រាប់អគារបៃតង — 2022-24
4. ការលើកទឹកចិត្ត — 2022-24
5. ការអភិវឌ្ឍន៍សមត្ថភាព — 2023

ផែនការអនុវត្ត

គោលដៅកាត់បន្ថយតាមអនុវិស័យនីមួយៗ

- 34% លំនៅដ្ឋាន
- 25% ពាណិជ្ជកម្ម
- 20% ឧស្សាហកម្ម
- 29% សេវាសាធារណៈ
- 5% ការដឹកជញ្ជូន

*គោលដៅកាត់បន្ថយ. ប្រភព : NEEP*

# រចនាសម្ព័ន្ធស្ថាប័ន

## គោលនយោបាយជាតិប្រសិទ្ធភាពថាមពល (NEEP)

**១. អនុគណៈកម្មាធិការជាតិប្រសិទ្ធភាពថាមពល ដឹកនាំដោយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (MISTI)**

បង្កើត និងអនុវត្តផែនការសកម្មភាពប្រសិទ្ធភាពថាមពលតាមវិស័យនៅក្នុងឧស្សាហកម្ម

**២. អនុគណៈកម្មាធិការជាតិប្រសិទ្ធភាពថាមពល ដឹកនាំដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (MLMUPC)**

បង្កើត និងអនុវត្តផែនការសកម្មភាពប្រសិទ្ធភាពថាមពលតាមវិស័យនៅក្នុងអគារ

**៣. អនុគណៈកម្មាធិការជាតិប្រសិទ្ធភាពថាមពល ដឹកនាំដោយក្រសួងសាធារណការ និងដឹកជញ្ជូន (MPWT)**

បង្កើត និងអនុវត្តផែនការសកម្មភាពប្រសិទ្ធភាពថាមពលតាមវិស័យក្នុងការងារសាធារណៈ និងដឹកជញ្ជូន

**៤. អនុគណៈកម្មាធិការជាតិប្រសិទ្ធភាពថាមពល ដឹកនាំដោយរដ្ឋបាលរាជធានី និងខេត្ត**

បង្កើត និងអនុវត្តផែនការសកម្មភាពប្រសិទ្ធភាពថាមពលតាមវិស័យ ដោយរួមបញ្ចូលជាមួយស្ថាប័នរដ្ឋបាលរាជធានី និងខេត្ត

គណៈកម្មាធិការជាតិប្រសិទ្ធភាពថាមពល




រចនាសម្ព័ន្ធអភិបាលកិច្ច NEEP

*ប្រភព: NEEP, Royal Government of Cambodia 2022 - 2030.*

# កម្មវិធី និងគម្រោងប្រសិទ្ធភាពថាមពល (EE)
## កម្ពុជា

**ត្រជាក់អកម្ម(Passive Cooling)នៅកម្ពុជា**

ក្រសួងបរិស្ថាន + ក្រុមប្រឹក្សាការត្រជាក់ + ESCAP

- អន្តរាគមន៍គោលនយោបាយតាមរយៈការរួមបញ្ចូល PCS ក្នុងការកសាងបទប្បញ្ញត្តិថាមពល។
- បង្ហាញកម្មវិធីត្រជាក់អកម្មនៅក្នុងអគារ។
- ផ្តល់ការលើកកម្ពស់ការយល់ដឹង និងការអភិវឌ្ឍសមត្ថភាពសម្រាប់ការប្រតិបត្តិឲ្យបានទូលំទូលាយ .
- គាំទ្រការដាក់បញ្ចូលការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ពី PCS នៅក្នុងគោលដៅវដ្តបន្ទាប់សម្រាប់ NDC របស់កម្ពុជា។

**ការប្រកួតប្រជែងប្រសិទ្ធភាពថាមពល**

CCCSP + CUBE

- ការបង្កើតការប្រកួតប្រជែងសម្រាប់ប្រសិទ្ធភាពថាមពលក្នុងអគារ ជាមួយនឹងគោលដៅនៃអគារអ្នកចូលរួមយ៉ាងតិច 25 សម្រាប់ឆ្នាំទី 1
- ឧបករណ៍ផ្លាស់ប្តូរឥរិយាបទនិងសម្ភារៈសម្របតាមបរិបទកម្ពុជាក្នុងស្រុក
- យុទ្ធនាការប្រព័ន្ធផ្សព្វផ្សាយសង្គមផ្តោតលើអ្នកទទួលផលជាច្រើន,
- ការចូលរួមរបស់និស្សិតតាមរយៈសមាគមយុវជន
- ការចែករំលែកឧត្តមានុវត្តរវាងសាកលវិទ្យាល័យ,
- ការពង្រឹងសមត្ថភាពអ្នកស្រាវជ្រាវ ITC ដើម្បីបង្កើតក្រុមអ្នកជំនាញដំបូងគេលើ EE នៅកម្ពុជា។
- របាយការណ៍ប្រឹក្សាគោលនយោបាយ និងកិច្ចប្រជុំជាមួយស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធ ដើម្បីចែករំលែកលទ្ធផលនៃការប្រលង និងដាក់ចេញរបៀបវារៈរបស់ EE

*ប្រភព :* *https://coolcoalition.org/pilot-projects/passive-cooling-in-cambodia/;*
*https://ncsd.moe.gov.kh/dcc/project/pushing-energy-efficiency-cambodia*

# កម្មវិធី និងគម្រោងប្រសិទ្ធភាពថាមពល (EE)

## កម្ពុជា

**ការសាកល្បងប្រសិទ្ធភាពថាមពលក្នុងអគារ និង បណ្ដាញមីក្រូសូឡា**

- ការធ្វើសវនកម្មនៅក្នុងអគាររដ្ឋាភិបាលចំនួន 5
- ការដំឡើងឧបករណ៍ត្រួតពិនិត្យថាមពលតាមពេលវេលាជាក់ស្ដែង (ផ្នែករឹង និងផ្នែកទន់)
- ការវិភាគទិន្នន័យថាមពល និងការជ្រើសរើសវិធានការប្រសិទ្ធភាពថាមពលដែលអាចធ្វើទៅបានសម្រាប់ការអនុវត្ត
- ការពិគ្រោះយោបល់ជាមួយនាយកដ្ឋានផែនការ/ហិរញ្ញវត្ថុ និង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បង្កើតគោលការណ៍ណែនាំលទ្ធកម្មប្រសិទ្ធភាពថាមពល
- ការគាំទ្របច្ចេកទេសនៃការអនុវត្តវិធានការប្រសិទ្ធភាពថាមពល
- គោលការណ៍ណែនាំសម្រាប់ការគ្រប់គ្រងថាមពលអគារ (BEM)
- បង្កើតកញ្ចប់ការបណ្ដុះបណ្ដាល និងអនុវត្តការបណ្ដុះបណ្ដាលគ្រូបង្គោល
- ចាប់ផ្ដើមកម្មវិធីបណ្ដុះបណ្ដាលគ្រប់គ្រងថាមពលអគារ សម្រាប់អ្នកគ្រប់គ្រង



*ប្រភព : https://ncsd.moe.gov.kh/dcc/project/piloting-energy-efficiency-and-solar-micro-grids*

# ប្រសិទ្ធភាពថាមពល (EE) ក្នុងវិស័យត្រជាក់

## ប្រតិបត្តិកម្មក្នុងអគារ និងឧស្សាហកម្ម

ផែនការសកម្មភាពសីតកម្មជាតិរបស់កម្ពុជា (NCAP)

ផែនការមេសម្រាប់អភិវឌ្ឍវិស័យថាមពល 2022-2040






# ផែនការសកម្មភាពសីតកម្មជាតិ (NCAP)

## ការស្នើសុំអន្តរាគមន៍គោលនយោបាយរយៈពេលខ្លី (៥ឆ្នាំ) និងរយៈពេលមធ្យម (១០ឆ្នាំ)

- បង្កើតក្រមអគារ និងការអនុវត្ត វិញ្ញាបនប័ត្រសម្រាប់អគារថ្មី និងអគារកែលម្អឡើងវិញ
- កាត់បន្ថយការពឹងផ្អែកលើម៉ាស៊ីនត្រជាក់នៅក្នុងអគារសាធារណៈ
- អនុម័តបទដ្ឋានគុណផលការប្រើប្រាស់ថាមពលអប្បបរមា(MEPS) និងការបិទស្លាកប្រសិទ្ធភាពថាមពលសម្រាប់ម៉ាស៊ីនត្រជាក់



# កម្ពុជា

ដំណើរឆ្ពោះទៅមុខ៖ ការអនុវត្តគោលនយោបាយ



Image source:https://ips-cambodia.com/cambodia-encourages-more-green-buildings/

# ដំណើរឆ្ពោះទៅមុខ

## ការអនុវត្តគោលនយោបាយប្រសិទ្ធភាពថាមពលអគារ

### ឧបសគ្គផ្នែកយោបាយ និងស្ថាប័ន

- ក្របខណ្ឌអភិបាលកិច្ចដែលមិនបានកំណត់លើប្រសិទ្ធភាពថាមពល រួមទាំងតួនាទី ភារកិច្ច និងយន្តការស្ថាប័ន សម្រាប់ការសម្របសម្រួលក្នុងចំណោមស្ថាប័នរដ្ឋាភិបាល។ កង្វះគោលនយោបាយ និងបទប្បញ្ញត្តិតាមវិស័យជាក់លាក់ ដើម្បីជំរុញការ វិនិយោគលើប្រសិទ្ធភាពថាមពល (ឧ. តាមរយៈក្រម ស្លាកសញ្ញា និងស្តង់ដារ)។
- កង្វះយន្តការទីផ្សារ និងបទប្បញ្ញត្តិដើម្បីគាំទ្រដល់ការអភិវឌ្ឍន៍សេវាប្រសិទ្ធភាពថាមពល និងការត្រួតពិនិត្យថាមពល ប្រើសម្រាប់ក្រមថាមពលអគារ ការរៀបចំក្រុមហ៊ុនផ្តល់សេវាដំណោះស្រាយថាមពល (អេស្កូ) និងអាជ្ញាប័ណ្ណសម្រាប់អ្នកត្រួតពិនិត្យថាមពល។
- កង្វះក្របខ័ណ្ឌ និងយន្តការអនុវត្តសម្រាប់ការវាស់វែង រាយការណ៍ និងការផ្ទៀងផ្ទាត់ការប្រើប្រាស់ថាមពលនៅក្នុងផ្នែកអ្នកប្រើប្រាស់ច្រើន រួមទាំងឧស្សាហកម្ម និង អគារ។
- ភាពមិនអាចរកបាននៃទិន្នន័យក្នុងអនុវិស័យ និងយន្តការចែករំលែកទិន្នន័យលើការប្រើប្រាស់ថាមពលពីក្រសួងមួយទៅក្រសួងមួយទៀត។
- កង្វះក្របខ័ណ្ឌការទទួលស្គាល់សម្រាប់សវនករថាមពល និងអ្នកគ្រប់គ្រងថាមពល។




*ប្រភព*: NEEP, Royal Government of Cambodia *2022 - 2030.*

# ដំណើរឆ្ពោះទៅមុខ

## ការអនុវត្តគោលនយោបាយប្រសិទ្ធភាពថាមពលអគារ

### ឧបសគ្គនផ្នែកយោបាយ និងស្ថាប័ន

- សមត្ថភាពនៅមានកម្រិតរបស់អាជ្ញាធររដ្ឋាភិបាលទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដើម្បីកំណត់ អភិវឌ្ឍន៍ និងអនុវត្តគម្រោងប្រសិទ្ធភាពថាមពល។
- កង្វះការលើកទឹកចិត្តផ្នែកសារពើពន្ធ និងហិរញ្ញវត្ថុ ដើម្បីគាំទ្រ និងផ្តល់រង្វាន់ដល់ការអនុវត្តប្រសិទ្ធភាពថាមពល។
- ការផ្គត់ផ្គង់អគ្គិសនីមិនគ្រប់គ្រាន់ តម្លៃអគ្គិសនីនៅខ្ពស់ និងបណ្តាញអគ្គិសនីមិនទាន់មានស្ថេរភាព ធ្វើឱ្យកម្ពុជាមានឱកាសពេញលេញខ្ពស់ផ្នែកទីផ្សារសម្រាប់ប្រសិទ្ធភាពថាមពល (EE) ។ ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា (CCCSP) សង្កត់ធ្ងន់លើសារៈសំខាន់នៃ EE ក្នុងវិស័យលំនៅដ្ឋាន និងអចលនទ្រព្យ។
- រៀបចំក្រមថាមពលអគារ
- អគ្គនាយកដ្ឋានថាមពល ក្រសួងរ៉ែ និងថាមពល ERIA បានបង្កើតផែនការមេ EEC សម្រាប់កម្ពុជា៖ (i) ក្រុមហ៊ុនផ្តល់សេវាដំណោះស្រាយថាមពល( អេស្កូ) (ii) បង្កើនចំនួនអ្នកគ្រប់គ្រងថាមពល (iii) ស្តង់ដារ និងប្រព័ន្ធស្លាកសញ្ញា (iv) ការអប់រំ និងយុទ្ធនាការ នឹង (v) ការរៀបចំសូចនាករប្រសិទ្ធភាពថាមពល (EEIs)




*ប្រភព*: *NEEP, Royal Government of Cambodia 2022 - 2030.*

# សេចក្តីថ្លែងអំណរគុណ

កម្មវិធីបណ្តុះបណ្តាលអគារកាបូនទាប (LCB) ដឹកនាំដោយវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (ITC) សម្រាប់រយៈពេល 2024-2027

## ដឹកនាំកម្មវិធីបណ្តុះបណ្តាលអគារកាបូនទាបដោយ៖

លោកស្រីបណ្ឌិត វង់ច័ន្ទ គីនណាលេត (អ្នកដឹកនាំ)

- អ៊ីម៉ែល៖ kinnalethv@yahoo.co.uk
- ទូរស័ព្ទលេខ៖ (+855) 99 351 199

លោកបណ្ឌិត ចាន់ សារិន្ទ (ទីប្រឹក្សា)

- អ៊ីម៉ែល៖ sarinchan@itc.edu.kh
- ទូរស័ព្ទលេខ៖ (+855) 99 351 199

លោកបណ្ឌិត ហ៊ាង ឡាទីន (អ្នកបច្ចេកទេស និងជំនួយការអ្នកគ្រប់គ្រង)

លោក ដា ចន្ទតុលា (អ្នកបច្ចេកទេស និងអ្នករៀបចំព្រឹត្តិការណ៍)

## អ្នកកែសម្រួល និងសម្របសម្រួលការបកប្រែ៖

លោកស្រីបណ្ឌិត វង់ច័ន្ទ គីនណាលេត

លោកបណ្ឌិត ហ៊ាង ឡាទីន

លោក វិធាន ខែមរដ្ឋ

លោក ដា ចន្ទតុលា

## សមាជិកអ្នកបកប្រែ៖

លោកបណ្ឌិត សាន វិបុល លោកបណ្ឌិត ជូ ផានិត

លោកបណ្ឌិត សេង ស៊ុនហ៊ រ លោកបណ្ឌិត អ៊ិត អ៊ូដាយ៉ាលោក លី

សូហេង លោក នុន សុផាន់ណា

កញ្ញា ហូ សូតាស៊ីង កញ្ញា ស្រ៊ុន ស្រីណា

លោក វិញ ឡាយអ៊ួ លោក លី លាងហុង

## អ្នកត្រួតពិនិត្យ៖

លោកបណ្ឌិត ចាន់ សារិន្ទ លោកបណ្ឌិត សាន វិបុល

លោកបណ្ឌិត សេង ស៊ុនហ៊ រ លោកបណ្ឌិត អ៊ិត អ៊ូដាយ៉ាលោក

បណ្ឌិត រៃ សុភ័ក្រ លោក លី សូហេង

លោក នុន សុផាន់ណា លោក ហាស់ ចាន់លី

លោក វិធាន ខែមរដ្ឋ លោកបណ្ឌិត ហ៊ាង ឡាទីន

# សូមអរគុណ

**សំគាល់៖** ឯកសារនេះត្រូវបានបកប្រែពីឯកសារដើមជាភាសាអង់គ្លេស និងកែសម្រួលតាមបរិបទបច្ចេកទេសថាមពល និងកាបូនទាបក្នុងវិស័យសំណង់អគារ។ ក្នុងករណីដែលលោកអ្នករកឃើញមានកំហុសឆ្គង ឬចង់ផ្តល់ជាមិតក្នុងការកែសម្រួល សូមផ្តល់ព័តមានមកកាន់គម្រោង ALCBT តាមរយៈអ៊ីម៉ែល៖ chan.suong@gggi.org ឬ heang.latin@itc.edu.kh

**យន្តការបណ្តឹងឯករាជ្យរបស់ ការផ្តួចផ្តើមអាកាសធាតុសកល (IKI)**

បុគ្គលណាដែលជឿថាពួកគេអាចរងផលប៉ះពាល់ដោយគម្រោង IKI ឬដែលចង់រាយការណ៍អំពីអំពើពុករលួយ ឬការប្រើប្រាស់មូលនិធិមិនត្រឹមត្រូវ អាចដាក់ពាក្យបណ្តឹងទៅកាន់យន្តការបណ្តឹងឯករាជ្យរបស់ IKI តាមរយៈ IKI-complaints@z-u-g.org។ យន្តការបណ្តឹងរបស់ IKI មានក្រុមអ្នកជំនាញឯករាជ្យដែលនឹងធ្វើការស៊ើបអង្កេតលើបណ្តឹងនោះ។ នៅក្នុងដំណើរការនៃការស៊ើបអង្កេត យើងនឹងពិគ្រោះយោបល់ជាមួយដើមបណ្តឹង ដើម្បីជៀសវាងហានិភ័យដែលមិនចាំបាច់សម្រាប់ដើមបណ្តឹង។ ព័ត៌មានបន្ថែមអាចរកបាននៅ https://www.international-climate-initiative.com/en/about-iki/values-responsibility/independent-complaint-mechanism/ ។

ព័ត៌មានទំនាក់ទំនង/អាសយដ្ឋាន

alcbt.gggi.org
@gggi_hq
@GGGIHQ

@GGGIHQ
@gggi_hq
@GGGIMedia

GGGI · ACE ASEAN Centre for Energy · EESL · HEAT

Supported by:
Federal Ministry for the Environment, Climate Action, Nature Conservation and Nuclear Safety
based on a decision of the German Bundestag

IKI INTERNATIONAL CLIMATE INITIATIVE